■ កម្ពុជាបាត់បង់លំហូរសាច់ប្រាក់ជិត៤ពាន់លានដុល្លារ ដោយសារកូវីដ-១៩ <ទំព័រ៖៣

■ សិទ្ធិគ្រប់គ្រងព្រៃឈើ និងផលផលផ្តល់ប្រយោជន៍ដល់ប្រជាជនកម្ពុជារាប់ម៉ឺននាក់និងអាចស្តារជីវៈចម្រុះធម្មជាតិ <ទំព័រ៖១០-១១

ការសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ សីហា | ឆ្នាំ ២០២១ | លេខទី ១៤២

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

AUGUST, 2021 | #142

## យុទ្ធនាការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ សម្រាប់កុមារចាប់ពីអាយុ០៦ឆ្នាំដល់ក្រោម១២ឆ្នាំ




ការចាក់វ៉ាក់សាំងជូនដល់កុមារអាយុចន្លោះពី ៦ឆ្នាំ ទៅ ១២ឆ្នាំនេះ គឺដើម្បីបង្កើតភាពស៊ាំក្នុងសង្គមឱ្យកាន់តែធំដែលអាចឈានទៅបើកលំហរសកម្មភាពក្នុងសង្គម ឱ្យកាន់តែទូលាយ បន្ថែមពីលើនេះគោលដៅសំខាន់ក្នុងការចាក់វ៉ាក់សាំងនេះ ដើម្បីឱ្យកុមារតូចៗអាចចូលរៀននៅសាលាឡើងវិញ។

កំណើនអត្រាចាក់វ៉ាក់សាំងកូវីដ-១៩ នៅកម្ពុជា គិតត្រឹមថ្ងៃទី៣ ខែតុលា ឆ្នាំ២០២១ មាន ៩៩,១២% ធៀបជាមួយចំនួនប្រជាជនគោលដៅ ១០លាននាក់ និងលើកុមារ-យុវវ័យអាយុពី ១២ឆ្នាំ ទៅក្រោម ១៨ឆ្នាំ មាន ៨៩,៦៤% ធៀបជាមួយចំនួនប្រជាជនគោលដៅ ១,៩៦៦,៩៣១ នាក់ និងលើកុមារអាយុពី ០៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ មាន ៩៣,០៨% ធៀបជាមួយនឹងប្រជាជនគោលដៅ ១,៨៩៧, ៣៨២ នាក់។

## រៀនរស់នៅក្នុងគន្លងថ្មី នៃបរិបទជំងឺឆ្លងកូវីដ១៩

# រៀនរស់នៅក្នុងគន្លងថ្មី នៃបរិបទជំងឺឆ្លងកូវីដ១៩









លោកអ្នកជាទីរាប់អាន! ក្នុងរយៈពេលប្រមាណជា២ឆ្នាំមកនេះ យើងម្នាក់ៗបានឆ្លងកាត់នូវបទពិសោធន៍ថ្មីសម្រាប់ជីវិត ដែលពោរពេញដោយការភ័យព្រួយ និងទុក្ខកង្វល់ ដែលបណ្តាលមកពីការរាលដាលនៃមេរោគឆ្លងកូវីដ១៩ ។ គ្រួសារខ្លះបានបាត់បង់សមាជិករបស់ខ្លួន ក្នុងរយៈពេលដ៏ខ្លី ញាតិមិត្តមិនអាចជូនដំណើរ ឬនិយាយលាគ្នាបាន គ្មានពិធីសាសនាក្នុងពេលមរណភាព ឯអ្នកខ្លះមានសុខភាពទ្រុឌទ្រោម ក្រោយព្យាបាលបានជាសះស្បើយពីជំងឺកូវីដ១៩ និងខ្លះភ័យស្លន់ស្លោរពេលស្ថិតក្នុងតំបន់ហាមឃាត់ ឬបិទខ្ទប់។

សកម្មភាពជាច្រើនត្រូវបានផ្អាកជាបន្តបន្ទាប់ និងរាំស្ទះជាដើម ដោយសារតែការប្រយុទ្ធប្រឆាំង កាត់ផ្តាច់ការឆ្លងរីករាលដាយនៃមេរោគដ៏សាហាវនេះ។

វិធានការជាច្រើន ដែលរដ្ឋជាអាណាព្យាបាលបានគិតពីសុខមាលភាពរបស់ប្រជាជន ហើយម្នាក់ៗត្រូវប្តូរទម្លាប់អនាម័យ ដោយពាក់ម៉ាស រក្សាគម្លាត មិនមានការជួបជុំ បិទសាលា គ្មានការសប្បាយអឹងកង គ្មានកម្មវិធីនានាក្នុងសហគមន៍។ សេដ្ឋកិច្ចក៏បានចាប់ផ្តើមលំបាក ទំនិញឡើងថ្លៃ តាមវិធីអ្នកជំនួញឆ្លៀតឱកាស។ ស្របពេលនេះការចាក់វ៉ាក់សាំងបង្ការក៏មានយុទ្ធនាការយ៉ាងឆាប់រហ័ស ដែលជាការទទួលខុសត្រូវទាំងស្រុងរបស់រាជរដ្ឋាភិបាលចាក់ជូនពលរដ្ឋ ចាប់ពីមនុស្សពេញវ័យ រហូតដល់កុមារអាយុ៦ឆ្នាំ។

ស្របពេលជាមួយគ្នានេះ បងប្អូនមួយចំនួនក៏បានល្មើសបំរាម បំពានវិធានផងដែរ ព្រោះតែការធុញថប់ តម្រូវការប្រចាំថ្ងៃនៃជីវភាព និងមូលហេតុផ្សេងៗទៀត។

បងប្អូនជាទីស្រលាញ់! សម្រាប់គ្រីស្តបរិស័ទដែលមានជំនឿលើព្រះគ្រីស្ត តើបងប្អូនមានបទពិសោធន៍នៃ ជំនឿយ៉ាងដូចម្តេចក្នុងគ្រានេះ? ដោយសារព្រះវិហារត្រូវផ្អាកសកម្មភាព ការជួបជុំ និងពិធីកម្មសាសនានានា។ តើបងប្អូនបានចូលរួមយ៉ាងណាខ្លះ ក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគឆ្លងដ៏សាហាវនេះ?

ពិតណាស់បងប្អូនអើយ! យើងម្នាក់ៗបានទទួលការត្រាស់ហៅយ៉ាងពិសេស ដើម្បីឱ្យទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូដោយទឹក និងព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងក៏ទទួលបានកិត្តិយសដ៏វិសេសវិសាលគឺជាបុត្រធីតារបស់ព្រះជាម្ចាស់ ជាព្រះបិតា។ យើងបានជឿថា ព្រះអង្គបានត្រាស់ហៅ តាមឈ្មោះម្នាក់ៗតាំងពីនៅក្នុងផ្ទៃម្តាយមកម្ល៉េះ (អេសាយ ៤៩,១)។ ព្រះអង្គត្រាស់ដោយសេចក្តីស្រលាញ់ និងព្រះហឫទ័យប្រណីសន្តោស។ តើបងប្អូនរួមជំនឿមានបទពិសោធន៍នេះដែរឬទេ?

តើព្រះអង្គត្រាស់យើងដើម្បីអ្វី? ពិតណាស់ គឺដើម្បីឱ្យម្នាក់ៗមានបទពិសោធន៍ក្នុងសេចក្តីស្រលាញ់ របស់ព្រះជាម្ចាស់ ដែលបានបង្ហាញឱ្យយើងបានស្គាល់តាមរយៈការបង្ហូរព្រះលោហិតចេញពីព្រះកាយព្រះបុត្រា សម្រាប់មនុស្សលោក។ ជាមួយគ្នានេះ ព្រះជាម្ចាស់ត្រូវការយើងដើម្បីចេញទៅប្រាប់បងប្អូន ចែករំលែកជាមួយបងប្អូនឯទៀតៗ នូវអ្វីដែលយើងម្នាក់ៗបានជឿ បានឮ បានទទួល ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ត។

យើងទទួលបានបេសកកម្មពិសេស ក្នុងការនាំអំណរសប្បាយ នាំការសង្គ្រោះ ដល់បងប្អូន ឱ្យបានស្គាល់ព្រះនាមព្រះយេស៊ូ បានវិញមករកព្រះជាម្ចាស់ជាព្រះបិតា បានទទួលកិត្តិយសដូចយើងជាបុត្រធីតារបស់ព្រះជាម្ចាស់។

ក្នុងបរិបទកូវីដ១៩ មេរោគបានឆ្លងពាសពេញពិភពលោក ជាពិសេសក្នុងប្រទេសកម្ពុជា មានកន្លែងច្រើនត្រូវបានបិទខ្ទប់ មនុស្សជាច្រើនដង្ហោយហៅរកជំនួយ ដោយខ្វះម្ហូបអាហារជាពិសេស ខ្វះខាតសម្ភារៈប្រើប្រាស់ដោយសារមិនបានត្រៀមទុក។ ព្រះសហគមន៍បានចេញសកម្មភាពយ៉ាងសកម្ម បម្រើដល់បងប្អូន ទាំងម្ហូបអាហារ និងផ្លូវវិញ្ញាណ គឺមានការអធិដ្ឋាន និងអភិបូជាតាមអនឡាញ (ONLINE) អង្វរព្រះជាម្ចាស់រួមគ្នា តាមរបៀបថ្មី សម្រាប់ថ្នាក់ដឹកនាំក្រុមគ្រូពេទ្យ និងអ្នកជំងឺ រួមទាំងគ្រួសារដែលមានទុក្ខព្រួយ។ ក្នុងនោះ យើងមិនត្រូវភ្លេចអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមកផងដែរ។

មនុស្សងាយណាស់ក្នុងការចាប់កំហុសរបស់អ្នកដទៃ វិនិច្ឆ័យបងប្អូនភ្លាមៗ តាមគំនិត និងរបៀបខាងក្រៅ។ ប៉ុន្តែព្រះជាម្ចាស់ត្រាស់យើង និងចាត់ឱ្យយើងចេះស្តាប់ ចេះទទួលបងប្អូន ដោយបេះដូងធំទូលំទូលាយ។ ចូលរួមក្នុងសកម្មភាពសង្គម និងព្រះសហគមន៍ដែលត្រូវការ គោរពវិធានការនានារបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ ដោយយកចិត្តទុកដាក់។ រស់នៅតាមការណែនាំ និងតាមរបៀបអ្នកជឿលើព្រះយេស៊ូគ្រីស្ត ទាំងសកម្មភាព និងពាក្យសំដី។

បងប្អូនជាទីរាប់អាន! សូមបន្តអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក បន្តលើកទឹកចិត្តគ្នាទៅវិញទៅមកកែតម្រូវគ្នា សេចក្តីស្រលាញ់ដែលមកពីព្រះជាម្ចាស់ជាបិតា ព្រមទាំងលើកលែងទោសឱ្យគ្នាទៅវិញទៅមក។ អ្នកម្តាយ តេរេសានៃក្រុងកុលកូថាមានប្រសាសន៍ថា៖ «ចូរចេញទៅក្នុងពិភពលោកនេះ ហើយស្រលាញ់បងប្អូនដែលអ្នកបានជួប។ សូមឱ្យវត្តមានរបស់អ្នក ជាពន្លឺថ្មីបំភ្លឺដួងចិត្តរបស់បងប្អូនឯទៀត» " Go out into the world today and love the people you meet. Let your present light new light in the people heart"៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# ក្រសួងប្រៃសណីយ៍ចាប់បើកចែកចាយឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ ពីរប្រភេទ សម្រាប់សាធារណជន

*អត្ថបទ៖ ផល សុផានិត*

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានទាន់ពេលវេលា ក្រសួងបើកទទួលចែកចាយឧបករណ៍តេស្តរហ័សជូនក្រសួង-ស្ថាប័ន ក្រុមហ៊ុន សហគ្រាស រោងចក្រ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង ភ្នាក់ងារចែកចាយ និងសាធារណជន នូវឧបករណ៍តេស្តរហ័សពីរប្រភេទ។




> ក្រសួងបើកទទួលចែកចាយឧបករណ៍តេស្តរហ័សជូនក្រសួង-ស្ថាប័ន ក្រុមហ៊ុន សហគ្រាស រោងចក្រ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង ភ្នាក់ងារចែកចាយ និងសាធារណជន

ឧបករណ៍តេស្តទាំងពីរនេះ មាន ឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ SD Biosensor (Standard Q) ផលិតនៅប្រទេសកូរ៉េ មួយ ប្រអប់មាន២៥ឧបករណ៍តេស្ត ហើយមួយឧបករណ៍តម្លៃ៣.៧ដុល្លារ(ត្បារយកសំណាកពីក្នុងរន្ធច្រមុះ)។ ឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ Healgen Antigen Rapid Test ផលិតនៅប្រទេសចិន ដែលក្នុងមួយប្រអប់មាន២០ឧបករណ៍តេស្ត ហើយមួយឧបករណ៍តេស្តតម្លៃ២ដុល្លារ (ត្បារយកសំណាកពីក្នុងរន្ធច្រមុះ)។

ក្រសួង-ស្ថាប័ន សហគ្រាស រោងចក្រ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង ភ្នាក់ងារចែកចាយ និងសាធារណជន អាចបញ្ជាទិញឧបករណ៍តេស្តចាប់ពីមួយប្រអប់ឡើងទៅ ដោយចូលទៅកាន់ប្រព័ន្ធស្វ័យប្រវត្តិកម្មដែលមានតំណភ្ជាប់ mptc.gov.kh/rt ឬ អញ្ជើញ មកទិញដោយផ្ទាល់នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជារៀងរាល់ថ្ងៃ៕

# កម្ពុជាបាត់លំហូរសាច់ប្រាក់ជិត៨ពាន់លានដុល្លារ ដោយសារកូវីដ-១៩

*អត្ថបទ៖ ផល សុផានិត*

ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យកម្ពុជាខាតបង់លំហូរហិរញ្ញប្បទានប្រមាណ៣,៦ ពាន់លានដុល្លារ ដែលស្មើនឹង១៩,៨ភាគរយនៃលំហូរហិរញ្ញវត្ថុសរុបសម្រាប់ឆ្នាំ២០២០ ។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ(UNDP) ប្រចាំកម្ពុជា ដោយបានបញ្ជាក់ថា ប្រភពហិរញ្ញប្បទានដែលកម្ពុជាខាតបង់ខ្លាំងជាងគេ មានចំណូលនៅក្នុងស្រុក, ការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) និងការវិនិយោគក្នុងស្រុកពីប្រភពឯកជន។

របាយការណ៍សិក្សាថ្មីមួយរបស់UNDP ដែលមានចំណងជើងថា«ការវាយតម្លៃលើធនធានហិរញ្ញប្បទាន សម្រាប់ការអភិវឌ្ឍនៅកម្ពុជា (DFA)» បានចេញផ្សាយកាលពីថ្ងៃទី១៦ កក្កដា ឆ្នាំ២០២១ ថា ចំណូលក្នុងស្រុកកាន់តែក្លាយជាប្រភពហិរញ្ញប្បទានសំខាន់បំផុតសម្រាប់ការអភិវឌ្ឍនៅកម្ពុជា ដែលស្មើនឹង ១៩ភាគរយនៃផលិតផលក្នុងស្រុកសរុប នៅក្នុងឆ្នាំ២០២០ ដោយប្រភពហិរញ្ញប្បទាន នឹងកើនរហូតដល់ ២២,៥ភាគរយនៅត្រឹមឆ្នាំ២០២៥ ។



របាយការណ៍របស់UNDPជាភាសាអង់គ្លេសដែលកម្រាស់ជាង៥០ទំព័រនោះ បានបង្ហាញថា លំហូរជំនួយអភិវឌ្ឍផ្លូវការដែលកម្ពុជាទទួលបាន គឺនៅមានកម្រិតគួរកត់សម្គាល់នៅឡើយដែល ស្មើនឹងប្រមាណ៧,៩ភាគរយនៃផលិតផលក្នុងស្រុកសរុប ខណៈផ្នែកខ្លះនៃហិរញ្ញប្បទាន ត្រូវបានបង្វែរទៅជាកម្ចីវិញ។

UNDP បានបញ្ជាក់ថា ៖ «ជំងឺកូវីដ-១៩ នាំឱ្យ[កម្ពុជា]មានការខាតបង់លំហូរហិរញ្ញប្បទានសរុបប្រមាណ ៣,៦ពាន់លានដុល្លារ ដែលស្មើនឹង ១៩,៨ភាគរយ នៃលំហូរហិរញ្ញវត្ថុសរុបសម្រាប់ឆ្នាំ២០២០»។

បើតាមរបាយការណ៍ដដែលរបស់UNDP ប្រភពហិរញ្ញប្បទានរបស់កម្ពុជាដែលរងផលប៉ះពាល់ខ្លាំងជាងគេក្នុងអំឡុងពេលនៃវិបត្តិកូវីដ-១៩នេះ មានប្រភពចំណូលក្នុងស្រុកដែលធ្លាក់ចុះ២៣,៦ភាគរយ។ ប្រភពចំណូលនេះ គឺធ្លាក់ចុះដោយសារការកាត់បន្ថយប្រាក់ចំណូលពន្ធលើសេដ្ឋកិច្ចធុន-តូច។

ការធ្លាក់ចុះនៃការវិនិយោគដោយផ្ទាល់ពីបរទេស ប្រមាណជាង៣០ភាគរយ ដោយសារផលប៉ះពាល់នៃខ្សែច្រវ៉ាក់ផលិតផលកម្មជាសកល ព្រមទាំងការខាតបង់ពីការវិនិយោគក្នុងស្រុកទៅលើវិស័យសំណង់និងទេសចរណ៍ផងដែរ។ ការខាតបង់ពីការវិនិយោគក្នុងស្រុកទៅលើវិស័យសំណង់និងទេសចរណ៍របស់កម្ពុជានេះ គឺអាចធ្លាក់ចុះនៅក្នុងរង្វង់៤០០លានដុល្លារ។

លោក Nick Beresford នាយក UNDP ប្រចាំកម្ពុជា បានឱ្យដឹងថា នេះជាលើកទីមួយហើយដែលមានការបង្កើតជាម៉ូដែល ដើម្បីបង្ហាញឱ្យឃើញពីរូបភាពពេញលេញនៃលំហូរចូលហិរញ្ញវត្ថុ ដែលគេរំពឹងថានឹងទទួលបានពីគ្រប់ប្រភពទាំងអស់សម្រាប់កម្ពុជា ជាមួយនឹងភាពជាក់លាក់បែបនេះ។

លោកថា ៖«នៅពេលដែលយើងអាចសម្រួលការរឹតត្បិត ដោយសារជំងឺកូវីដ-១៩ គេរំពឹងថា រំហូរធនធានហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ នឹងមានកំណើនខ្ពស់»។

លោក Nick Beresford បានបញ្ជាក់ថា ក្នុងចំណោមលំហូរទាំងនេះ ប្រភពហិរញ្ញប្បទានពីក្នុងស្រុក កាន់តែមានសារៈសំខាន់ខ្លាំងឡើង។

នាយកUNDP ប្រចាំកម្ពុជារូបនេះ បានបន្តលើកឡើងថា ៖ « កម្ពុជា អាចងើបចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួច នៅចុងទសវត្សរ៍២០២០។ ពេលនេះហើយ ជាពេលវេលាដែលត្រូវត្រៀមប្រភពហិរញ្ញប្បទានថ្មីៗ ដូចដែលបង្ហាញយ៉ាងច្បាស់នៅក្នុងរបាយការណ៍នេះ។ ឧទាហរណ៍ ការមានលទ្ធភាពចេញសញ្ញាប័ណ្ណជាប្រាក់រៀល គឺជាជម្រើសមួយដែលកំពុងត្រូវបានយកមកធ្វើការពិចារណា ហើយក៏ជាជម្រើសដែលទទួលបានការគាំទ្រខ្លាំងក្លាពី UNDP ផងដែរ»។

សម្រាប់រដ្ឋាភិបាលកម្ពុជាផ្ទាល់ គឺមានគម្រោងផ្សព្វផ្សាយផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ សម្រាប់ឆ្នាំ២០២១-២០២៣ ដែលនឹងប្រើប្រាស់ហិរញ្ញប្បទានពីថវិកាជាតិ និងពិចារណាកៀរគរប្រភពហិរញ្ញប្បទានផ្សេងទៀតផងដែរ។ នេះជាប្រសាសន៍របស់លោក រស់ សីលវ៉ា រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបានបញ្ជាក់ថារបាយការណ៍របស់UNDP នេះ នឹងផ្តល់នូវគំនិតបន្ថែមពីជម្រើសប្រភពហិរញ្ញប្បទានដទៃទៀតសម្រាប់កម្ពុជា។

លោក សីលវ៉ា បានស្វាគមន៍អនុសាសន៍គោលនយោបាយដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍ DFA នេះផងដែរ។ លោកបាននិយាយដូច្នេះ ៖ «ការផ្តល់អនុសាសន៍គោលនយោបាយឈរលើភ័ស្តុតាងដល់រាជរដ្ឋាភិបាលកម្ពុជា គឺជាការរួមវិភាគទានបន្ថែមទៀតរបស់ UNDP»៕

# ចិនផ្តល់ជំនួយ២,៩លាន ចោសសំអាតមីននៅកម្ពុជា

*អត្ថបទ៖ ផល សុផានិត*



លោក ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា (CMAC) នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បានបញ្ជាក់ថា រដ្ឋាភិបាលចិនបានសម្រេចផ្តល់ជំនួយឥតសំណង មានទឹកប្រាក់សរុបចំនួន ២, ៩លានដុល្លារ ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រសកម្មភាពបោសសម្អាតមីន និងសំណល់ជាតិផ្ទុះ ពីសង្គ្រាមរបស់អង្គភាពស៊ីម៉ាក់ សំរាប់រយៈពេល១២ខែ ឆ្នាំ២០២២ ។

លោក ហេង រតនា បានបញ្ជាក់ថា គម្រោងនេះនឹងត្រូវប្រើប្រាស់កម្លាំងប្រតិបត្តិការជិត៣០០នាក់ សម្រាប់បោសសម្អាតមីន នៅខេត្តព្រះវិហារ ឧត្តរមានជ័យ ស្ទឹងត្រែង ខេត្តសៀមរាប និងខេត្តកំពង់ធំ ដោយផែនការត្រូវរំដោះផ្ទៃដីចំការមីន និងចំការសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួនជាង១៧០០ហិចតា និងសកម្មភាពអប់រំយល់ដឹងពីគ្រោះថ្នាក់ ដោយសារមីនចំនួន៧ខេត្ត។

អគ្គនាយកស៊ីម៉ាក់រូបនេះបន្តថា សម្រាប់លទ្ធផលរយៈពេល៦ខែ ឆ្នាំ២០២១នេះ គំរោងជំនួយចិនលុបបំបាត់គ្រាប់មីននៅកម្ពុជា ដែលបានផ្តល់ជំនួយឥតសំណង មានទំហំថវិកាដូច ២០២២ ដែរ នោះ និងបានរំដោះដីចំការមីន/គ្រាប់សំណល់ជាតិផ្ទុះ ចំនួ នជិត១០៨៣ហិចតា រុករកឃើញកំទេចគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួ នជាង៥០០០គ្រាប់។

លោក ហេង រតនា បានបញ្ជាក់ទៀតថា ៖ «សូមគោរពអរគុណជាអនេកចំពោះសម្តេចតេជោប្រមុខរាជរដ្ឋាភិបាល ដែលបានជំរុញសំណើគាំទ្រថវិកានេះ ជាមួយប្រធានាធិបតីចិន ហើយជាបន្តបន្ទាប់រដ្ឋាភិបាលចិន បានឆ្លើយតបតាមសំណូមពររបស់សម្តេចតេជោ»។

លោកបន្តថា តាងនាមអង្គភាពស៊ីម៉ាក់ ក៏ដូចជនរងគ្រោះដោយសារមីន សូមសំដែងនូវការដឹងគុណ ជូនចំពោះប្រជាជននិងរដ្ឋាភិបាលចិន ដែលបានគាំទ្រថវិកាមនុស្សធម៌ ដ៏មានសារសំខាន់នេះ សំរាប់ទ្រទ្រង់សកម្មភាពអង្គភាពស៊ីម៉ាក់ ក្នុងការរំដោះគ្រាប់មីន និងសំណល់យុទ្ធភណ្ឌពីសង្គ្រាម ផ្តល់សុខសុវត្ថិភាព និងគាំទ្រការអភិវឌ្ឍនៅកម្ពុជា៕

# ស្ថាប័នរដ្ឋនិងឯកជនត្រូវធ្វើតេស្តជាប្រចាំលើបុគ្គលិកឲ្យបាន៥-១០%

*អត្ថបទ៖ ផល សុផានិត*

រាជរដ្ឋាភិបាលកម្ពុជា បានជំរុញឱ្យ ស្ថាប័នរដ្ឋ និងឯកជនទាំងអស់ ធ្វើតេស្តរហ័សរកមេរោគកូវីដ១៩ ទៅលើមន្ត្រី និងបុគ្គលិករបស់ខ្លួនប្រមាណ ៥ទៅ១០ភាគរយជាប្រចាំ យ៉ាងហោចណាស់ឱ្យបាន ១ដង ក្នុងចន្លោះ ១-២សប្តាហ៍ ដើម្បីរួមចំណែកក្នុងការរុករកវត្តមាននៃអ្នកផ្ទុកមេរោគកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។ នេះបើតាមគោលការណ៍ណែនាំទូទៅស្តីពី ការគ្រប់គ្រង និងប្រើប្រាស់តេស្តរហ័សរក អង់ទីហ្សែនកូវីដ១៩ ។

ក្នុងគោលការណ៍ណែនាំនេះ រាជរដ្ឋាភិបាលបានបញ្ជាក់ថា ដោយសារការ ធ្វើតេស្តរហ័សចំណាយរយៈពេលខ្លី និងប្រើប្រាស់ថវិកាតិច ឧបករណ៍តេស្តរហ័សនេះ នឹងចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៅក្នុងសហគមន៍ និងការរុករកករណីលាក់បាំង (ដូចជាករណីដែលមិនមានរោគសញ្ញា) ដើម្បីរក្សានិរន្តរភាពការងារនៅតាមទីតាំងមួយចំនួន ដូចជា គ្រឹះស្ថានសេវាសុខាភិបាលសាធារណៈរបស់រដ្ឋ និងឯកជន, ស្ថាប័ន និងអង្គភាពរដ្ឋមិនមែនសុខាភិបាល, ក្រុមហ៊ុនឯកជន, រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំក្នុងការដ្ឋាន សំណង់, ទីផ្សារ, ធនាគារ, មណ្ឌលកម្សាន្តនានា និងទីកន្លែងអាជីវកម្មផ្សេងទៀត ដែលមានសារសំខាន់ ចំពោះកិច្ចបើកដំណើរការពេញលេញនៃសកម្មភាពសង្គម-សេដ្ឋកិច្ច តាមគន្លងប្រក្រតីភាពថ្មី។ ដូច្នេះការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការរុករកវត្តមាននៃអ្នកផ្ទុកមេរោគកូវីដ-១៩ នៅតាមទីតាំងទាំងនោះ ។

គោលការណ៍ណែនាំទូទៅស្តីពី ការគ្រប់គ្រង និងប្រើប្រាស់តេស្តរហ័សរក អង់ទីហ្សែនកូវីដ១៩ ចំនួន២៦ទំព័រ បានបញ្ជាក់បន្ថែមថា ក្នុងន័យនេះ ដើម្បីពង្រឹងយន្តការកាត់បន្ថយហានិភ័យនៃវត្តមានរបស់អ្នកផ្ទុកមេរោគកូវីដ-១៩ នៅតាមទីតាំងខាងលើគោលការណ៍ណែនាំប្រតិបត្តិសម្រាប់ការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមស្ថាប័នរដ្ឋ ឬឯកជននានា ត្រូវមានការរៀបចំឡើងជាលម្អិត ដែលប្រធានស្ថាប័ន ឬអង្គភាពទទួលបន្ទុក គួរអនុវត្តតាមវិធានការដូចខាងក្រោម៖

- រៀបចំផែនការធ្វើតេស្តរហ័សតាមបែបជម្រើសដោយចៃដន្យ ដែលមានលក្ខណៈជាវដ្ត (Periodic) និងសមស្របនឹងហានិភ័យស្ថាប័ន ឬអង្គភាព និងប្រព្រឹត្តទៅជាប្រចាំលើបុគ្គលិកចំនួនយ៉ាងតិច ៥-១០% នៃបុគ្គលិកក្នុងស្ថាប័ន ឬអង្គភាព (ដោយក្នុងសំណាកនីមួយៗត្រូវមានបុគ្គលិកដែលមានទីតាំងលំនៅដ្ឋានក្នុងតំបន់ខុសៗគ្នា) ។ ផែនការនេះគួរធានាថា បុគ្គលិកទាំងអស់ ដែលមានវត្តមានលើបរិវេណស្ថាប័ន ឬអង្គភាព ទទួលបានការ ធ្វើតេស្តរហ័សជាប្រចាំ (យ៉ាងតិច ១ ដង ក្នុងចន្លោះ ១ ទៅ ២ សប្តាហ៍)។ ស្ថាប័ន ឬ អង្គភាពនីមួយៗ ត្រូវផ្សព្វផ្សាយឱ្យបានច្បាស់លាស់ និងទូលំទូលាយអំពីផែនការនៃការធ្វើ តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ របស់ខ្លួន។
- កំណត់បុគ្គលិកដែលមានហានិភ័យខ្ពស់ដូចជាបុគ្គលិកដែលមានការប្រាស្រ័យទាក់ទង ជាមួយបុគ្គលិកផ្សេងទៀត ឬមនុស្សក្រៅស្ថាប័ន ឬអង្គភាពច្រើន រួចធ្វើតេស្តរហ័សឱ្យញឹកញាប់លើបុគ្គលិកទាំងនោះ។
- ប្រសិនបើមានករណីវិជ្ជមាន ឬមានការផ្ទុះនៃជំងឺកូវីដ-១៩ ត្រូវអនុវត្តតាមគោលការណ៍ ណែនាំប្រតិបត្តិស្តីពីការប្រើប្រាស់តេស្តរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់គ្រឹះស្ថាន សុខាភិបាលឯកជន, ស្ថាប័ន និងអង្គភាពរដ្ឋមិនមែនសុខាភិបាល, បណ្តាច្រកទ្វារចេញ- ចូលប្រទេស, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស និងទីកន្លែងអាជីវកម្មផ្សេងទៀត និង សម្រាប់បុគ្គលឯកជន របស់ក្រសួងសុខាភិបាល ដែលបានដាក់ចេញឱ្យអនុវត្ត កាលពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២១ ។
- ក្នុងករណីមានលទ្ធផលតេស្តរហ័សវិជ្ជមានលើបុគ្គល ដែលត្រូវបានចាត់ទុកថាជាបុគ្គលមាន ហានិភ័យទាប (ឧទាហរណ៍ ស្នាក់នៅតំបន់មានអត្រាប្រេវ៉ាឡង់នៃការចម្លងទាប និងមិន មានប៉ះពាល់ផ្ទាល់ជាមួយអ្នកមានផ្ទុកមេរោគកូវីដ-១៩) ស្ថាប័ននីមួយៗត្រូវដាក់បុគ្គល នោះនៅដោយឡែក និងស្នើឱ្យមានការធ្វើតែស្ត PCR បញ្ជាក់ មុននឹងបញ្ជូនបុគ្គលនោះទៅ ព្យាបាល។
- អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់ការសម្របសម្រួល កិច្ចសហការ និងការគាំទ្រដល់វិស័យ ឯកជន ឬ ម្ចាស់អាជីវកម្មនីមួយៗក្នុងការត្រៀមរៀបចំ និងអនុវត្តកម្មវិធីធ្វើតេស្តរហ័ស ដែលមាននៅតាមមូលដ្ឋានរបស់ខ្លួនតាមការចាំបាច់។

ជាមួយគ្នានេះ សម្រាប់គ្រឹះស្ថានសុខាភិបាលសាធារណៈរបស់រដ្ឋ និងឯកជន ដែលជាទីតាំង មានហានិភ័យខ្ពស់ និងអាចក្លាយជាទីតាំងបម្រើឱ្យការធ្វើតេស្តរហ័សផងនោះ ទីតាំងទាំងនេះចាំបាច់ ត្រូវមានការរៀបចំផែនការអនុវត្តមួយចំនួនបន្ថែមទៀត តាមគោលការណ៍ណែនាំប្រតិបត្តិស្តីពីការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់គ្រឹះស្ថានសុខាភិបាលឯកជន, ស្ថាប័ន និងអង្គភាព រដ្ឋមិនមែនសុខាភិបាល, បណ្តាច្រកទ្វារចេញ-ចូលប្រទេស, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស និងទីកន្លែងអាជីវកម្មផ្សេងទៀត និងសម្រាប់បុគ្គលឯកជន របស់ក្រសួងសុខាភិបាល ដែលបានដាក់ចេញឱ្យអនុវត្ត កាលពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២១។



# ក្រសួងសុខាភិបាលពន្យល់ការឆ្លងកូវីដ១៩ សម្រាប់អ្នកចាក់វ៉ាក់សាំងរួច

*អត្ថបទ៖ ផល សុផានិត*

បើទោះបីមានការចាក់វ៉ាក់សាំងបានច្រើនហើយក្តី តែអត្រានៃអ្នកឆ្លងជំងឺកូវីដ១៩ ក៏ដូចជាអ្នកស្លាប់ដោយសារជំងឺនេះ នៅតែមានចំនួនច្រើនគួរឱ្យបារម្ភ។

បញ្ហានេះនាំឱ្យមានការងឿងឆ្ងល់ទៅលើគុណភាពវ៉ាក់សាំងរបស់ចិនស៊ីណូហ្វាម និងស៊ីណូវ៉ាក់ ដែលកម្ពុជាបានចាក់ជូនប្រជាពលរដ្ឋ។ ក្នុងនោះក៏មានជនអគតិមួយចំនួនបានឆ្លៀតយកបញ្ហានេះ វាយតម្លៃដោយអត្តនោម័ត និងគ្មានមូលដ្ឋានបច្ចេកទេសវេជ្ជសាស្ត្រថា វ៉ាក់សាំងរបស់ចិន គ្មានគុណភាព ឬប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស បានលើកឡើងថា វ៉ាក់សាំងរបស់ចិនទាំងពីរប្រភេទ ដែលកំពុងប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា គឺមានប្រសិទ្ធភាពដូចវ៉ាក់សាំងដទៃទៀត ដែរ។

លោកស្រី បានអះអាងថា មុននឹងសម្រេចដាក់ឱ្យប្រើប្រាស់បន្ទាន់ចំពោះវ៉ាក់សាំងស៊ីណូហ្វាម និងស៊ីណូវ៉ាក់ ក៏ដូចជាវ៉ាក់សាំងដទៃទៀត គឺអង្គការសុខភាពពិភពលោក បានសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើប្រសិទ្ធភាព និងសុវត្ថិភាពនៃវ៉ាក់សាំង។

លោកស្រី ឱ វណ្ណឌីន មានប្រសាសន៍ថា ៖ «ខ្ញុំសូមជម្រាបថា មុននឹងអង្គការសុខភាពពិភពលោកគេដាក់នូវវ៉ាក់សាំងឱ្យប្រើប្រាស់ គឺអង្គការសុខភាពពិភពលោក ដែលយើងហៅថា WHO បានសិក្សាហ្មត់ចត់ណាស់ទៅលើប្រសិទ្ធភាព និងសុវត្ថិភាពវ៉ាក់សាំង។ អ៊ីចឹងវ៉ាក់សាំងអីក៏ដោយ ទោះ បីវ៉ាក់សាំងស៊ីណូហ្វាម ស៊ីណូវ៉ាក់ ភីហ្វាយស័រ ចនសុនចនសុន អាស្ត្រាហ្សេនីកា ឬក៏ម៉ូដេណា គឺសុទ្ធសឹងជាវ៉ាក់សាំង ដែលមានប្រសិទ្ធភាព មានសុវត្ថិភាពប្រើប្រាស់នៅលើមនុស្ស»។

នៅកម្ពុជាក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ការឆ្លងនៃជំងឺកូវីដ១៩ មានអត្រាមួយខ្ពស់ ហើយការស្លាប់ក៏មានច្រើនផងដែរ។

ឆ្លើយតបបញ្ហានេះ លោកស្រី ឱ វណ្ណឌីន បានគូសបញ្ជាក់ថា នៅពេលដែលកម្ពុជាចាប់ផ្តើមចាក់វ៉ាក់សាំង គឺជំងឺកូវីដ១៩ បានចាប់ផ្តើមរាតត្បាតខ្លាំងនៅក្នុងប្រទេសកម្ពុជារួចទៅហើយ ហើយការចាក់វ៉ាក់សាំងហើយភ្លាមៗ ក៏មិនទាន់អាចបង្កើតកងការពារទៅប្រយុទ្ធនឹងមេរោគកូវីដ១៩បានភ្លាមៗនោះដែរ។

ក្រៅតែពីបញ្ហាវេជ្ជសាស្ត្រ ការដែលប្រជាពលរដ្ឋមួយចំនួន អនុវត្តមិនបានខ្ជាប់ខ្ជួននូវវិធានការពារជំងឺកូវីដ១៩ ដូចជាវិធាន «៣ការពារ និង៣កុំ» រួមនឹងការមើលស្រាល និងប្រមាថចំពោះជំងឺកូវីដ១៩ ក៏ជាកត្តានាំឱ្យមានការឆ្លងរីករាលដាលផងដែរ។ នេះជាការបញ្ជាក់បន្ថែមរបស់លោកស្រី ឱ វណ្ណឌីន។

> អ្នកដែលស្លាប់ភាគច្រើនជាមនុស្សមានវ័យចំណាស់ រស់នៅតាមទីជនបទ ហើយពេលកើតជំងឺកូវីដ១៩មិនបានដឹង ដោយស្មានតែជំងឺផ្តាសាយ នាំឱ្យជំងឺវាយលុកសុខភាពខ្លាំង មិនអាចជួយសង្គ្រោះបាន

ពាក់ព័ន្ធនឹងអ្នកស្លាប់វិញ លោកស្រី ឱ វណ្ណឌីន បានគូសបញ្ជាក់ថា មិនទាន់មានការសិក្សាស្រាវជ្រាវឱ្យបានច្បាស់លាស់នៅឡើយនោះទេ ហើយលោកស្រី ក៏កំពុងរៀបចំក្រុមការងារសិក្សាលើបញ្ហានេះផងដែរ។

តែទោះជាយ៉ាងណា ក៏មានការសម្ភាសន៍ផ្ទាល់មាត់មួយចំនួនពាក់ព័ន្ធនឹងការស្លាប់នេះ។ លោកស្រី ឱ វណ្ណឌីន បានគូសបញ្ជាក់ថា ឆ្លងតាមការសម្ភាសន៍ផ្ទាល់មាត់ គឺបានបង្ហាញថា អ្នកដែលស្លាប់ភាគច្រើនជាមនុស្សមានវ័យចំណាស់ រស់នៅតាមទីជនបទ ហើយពេលកើតជំងឺកូវីដ-១៩មិនបានដឹង ដោយស្មានតែជំងឺផ្តាសាយ នាំឱ្យជំងឺវាយលុកសុខភាពខ្លាំង មិនអាចជួយសង្គ្រោះបាន។

លោកស្រី ឱ វណ្ណឌីន បន្តក្រើនរំលឹក និងអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវតែប្រកាន់ខ្ជាប់នូវស្មារតីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ទាំងអស់គ្នា ដើម្បីយកឈ្នះលើការរាតត្បាតនៃជំងឺ។ ជាពិសេសការអនុវត្តវិធានសុខាភិបាល «៣ការពារ និង៣កុំ» ហើយកាត់បន្ថយការធ្វើដំណើរបើគ្មានករណីចាំបាច់ទេនោះ។

លោកស្រី បានអះអាងថា មានតែការចាក់វ៉ាក់សាំង ហើយបន្តអនុវត្តនូវវិធានសុខាភិបាលទាំងនេះទេ ទើបអាចបង្ការការរាតត្បាតជំងឺកូវីដ១៩ ៕

# កំណត់ត្រា១០ទីតាំងនៃសត្វក្រៀលនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

យោងតាមជំរឿនសត្វក្រៀលនៅចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០ សត្វក្រៀលចំនួន ១៩៤ ក្បាលត្រូវបានកត់ត្រានៅប្រមាណ ១០ទីតាំងខុសៗគ្នានៅក្នុងប្រទេសកម្ពុជា។ ការជំរឿននេះ ធ្វើឡើងនៅរាល់ខែធ្នូ ដល់ខែឧសភា នៃឆ្នាំនីមួយៗ ដើម្បីអាចឱ្យយើងប៉ាន់ស្មាន និងពិនិត្យតាមដានពីចំនួនសត្វក្រៀលថាតើវាកើនឡើង ឬថយចុះ និងដើម្បីរៀបចំយន្តការ និងផែនការការពារនិងអភិរក្សបន្ថែមទៀត។ នេះបើតាមការលើកឡើងរបស់លោកនេត្រ ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថាន។



សត្វក្រៀលគឺជាប្រភេទសត្វកម្រ និងជាសត្វស្លាបដែលមានកម្ពស់ខ្ពស់ជាងគេនៅលើពិភពលោក ហើយអាចហើរបាន ត្រូវបានរកឃើញថាមាននិន្នាការធ្លាក់ចុះខ្លាំង ក្នុងនោះសត្វក្រៀលនៅកម្ពុជាក៏មានចំនួនធ្លាក់ចុះដែរ ដែលទាំងអស់គ្នាចាំបាច់ត្រូវចូលរួមការពារ និងអភិរក្សប្រភេទសត្វដ៏កម្រនេះ ទាំងការថែរក្សាទីជម្រកពងកូន និងតំបន់ដីសើមដែលជាកន្លែងស្វែងរកចំណីរបស់សត្វក្រៀលនិងសត្វស្លាបផ្សេងៗទៀត។

លោក នេត្រ ភក្ត្រា ថា យោងតាមទិន្នន័យសិក្សាដោយអ្នកជំនាញ ចំនួនសត្វក្រៀល នៅលើពិភពលោកនាពេលបច្ចុប្បន្ននេះ មានចំនួនចន្លោះពី ១៣.០០០ ទៅ១៥.០០០ ក្បាលដែលកំពុងរស់នៅក្នុងប្រទេសឥណ្ឌា ប្រទេសអូស្ត្រាលី ប្រទេសវៀតណាម ប្រទេសឡាវ និងប្រទេសកម្ពុជា។

សត្វក្រៀលមានវត្តមាននៅក្នុងប្រទេសកម្ពុជាតាំងពីយូរលង់ណាស់មកហើយ ហើយបើបានទស្សនាប្រាសាទបាយ័ននៅខេត្តសៀមរាប នោះនឹងឃើញរូបចំលាក់សត្វក្រៀលដែលត្រូវបានឆ្លាក់ជាប់នឹងផ្ទាំងថ្ម។ នៅក្នុងទ្វីបអាស៊ី សត្វក្រៀលគឺជានិមិត្តរូបនៃជោគវាសនាល្អ និងអាយុយឺនយូរ។

ពួកវាក៏ត្រូវបានគេគិតថាជានិមិត្តរូបនៃមនោសញ្ចេតនាស្នេហាស្មោះត្រង់ ដោយយោងទៅតាមការភ្ជាប់ចំណងមេត្រីភាពរបស់ពួកវា។ នៅក្នុងប្រទេសភូមា សត្វក្រៀលត្រូវបានគេឃើញមានក្នុងពុទ្ធសាសនា។

លោក នេត្រ ភក្ត្រា បានលើកឡើងពីកត្តាគំរាមកំហែងចំពោះសត្វក្រៀលដោយបានពន្យល់ថា៖ «ចំនួនសត្វក្រៀលត្រូវបានធ្លាក់ចុះយ៉ាងច្រើន





នាប៉ុន្មានឆ្នាំកន្លងមកនេះដោយសារតែអត្រាស្លាប់កម្រិតខ្ពស់ និងអត្រាបង្កកំណើតមានកម្រិតទាបនៅឡើយ»។ លោកថា ការធ្លាក់ចុះចំនួនសត្វក្រៀលនៅទូទាំងពិភពលោកនេះគឺបណ្តាលមកពីកត្តាគំរាមកំហែងផ្សេងៗដែលបង្កឡើងដោយមនុស្ស និងធម្មជាតិ ដូចជាការបាត់បង់តំបន់ដីសើមដែលជាទីជម្រកដ៏សំខាន់របស់សត្វក្រៀល ការរំខាននៅតំបន់ពងកូន ដែលនាំឱ្យអត្រាបង្កកំណើតទាប ការបំពុលដោយថ្នាំពុលកសិកម្ម ការថយចុះនូវវត្តមានចំណីអាហារ ការកែប្រែប្រព័ន្ធជលសាស្ត្រ ជំងឺឆ្លង ការយកស៊ុត ឬកូនសត្វក្រៀលពីសំបុក ដើម្បីចិញ្ចឹម ឬជួញដូរ ការសម្លាប់ដោយសត្វឆ្កែខាំ និងការប្រែប្រួលអាកាសធាតុជាដើម។

លោកបានថ្លែងថា ក្រសួងបរិស្ថានបាននិងកំពុងសហការជាមួយអង្គការដៃគូក្នុងការអភិរក្សសត្វក្រៀល និងទីជម្រករបស់ពួកវាដោយឧទ្យានុរក្ស តែងតែល្បាតនៅតំបន់ការពារធម្មជាតិដែលជាជម្រករបស់សត្វក្រៀល ការសិក្សាពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រង និងដាក់តំបន់ដីសើមសំខាន់ៗជាតំបន់ការពារធម្មជាតិ និងធ្វើជំរឿនសត្វក្រៀលជារៀងរាល់ឆ្នាំ ដើម្បីប្រមូលនិងរក្សាទុកទិន្នន័យជាក់លាក់នៃចំនួនសត្វក្រៀលនៅប្រទេសកម្ពុជា។

លោក នេត្រ ភក្ត្រា បានមានប្រសាសន៍ថា៖ «យើងក៏បានលើកទឹកចិត្តដល់សកម្មភាពអភិរក្ស និងលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានតាមរយៈទេសចរណ៍ធម្មជាតិ និងការសាកល្បងធ្វើស្រូវមិត្តក្រៀល។ លើសពីនេះទៀត យើងបានធ្វើការអប់រំផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីសត្វក្រៀលដល់សាធារណៈ និងតែងតែរៀបចំប្រារព្ធទិវាតំបន់ដីសើមពិភពលោក និងទិវាសត្វស្លាបទេសន្តរប្រវេសន៍ពិភពលោកជាដើម»។

ទាក់ទងនឹងទីជម្រកសត្វក្រៀលនៅកម្ពុជា លោក ស្រី ស៊ុនលាង អគ្គនាយករងនៃអគ្គនាយកដ្ឋាន រដ្ឋបាលការពារនិងអភិរក្សធម្មជាតិ បានឱ្យដឹងថា សត្វក្រៀលប្រើប្រាស់ទីជម្រកផ្សេងៗគ្នាដែលមានវិសាលភាពធំគ្របដណ្តប់ទូទាំងប្រទេសកម្ពុជា ដែលនេះជាតម្រូវការនានា នៅរដូវកាលផ្សេងៗគ្នាសម្រាប់សត្វក្រៀល។

លោកថា៖ «នៅរដូវពងកូនចាប់ពី ខែកក្កដា ដល់ខែតុលា សត្វក្រៀលធ្វើបំលាស់ទីទៅភាគខាងជើង និងភាគឦសាន(ខាងជើងឈាងខាងកើត) នៃប្រទេសកម្ពុជា។ នៅក្នុងព្រៃដែលសំបូរដោយ តំបន់ដីសើមតូច(ត្រពាំង ឬថ្លុកទឹក) គឺជាទីជម្រកដ៏សំខាន់សម្រាប់បន្តពូជ»។

លោកបានបន្តថា នៅរដូវរកចំណីមិនបន្តពូជ ចាប់ពី ខែធ្នូ ដល់ ខែមេសា សត្វក្រៀលធ្វើការផ្លាស់ទីទៅភាគពាយ័ព្យ(ខាងជើងឈាងខាងលិច) និងភាគអាគ្នេយ៍ (ខាងត្បូងឈាងខាងកើត) នៃប្រទេសកម្ពុជា ដែលជាទីជម្រកដ៏សំខាន់សម្រាប់រកចំណីបំប៉នសុខភាពសម្រាប់រដូវបន្តពូជ។

សត្វក្រៀលធ្វើការផ្លាស់ទីពីទីតាំងបន្តពូជទៅទីតាំងរកចំណីនៅចន្លោះខែតុលា និងខែវិច្ឆិកា អាស្រ័យលើស្ថានភាពរដូវវស្សាប្រចាំឆ្នាំ។ ពួកវាធ្វើការផ្លាស់ទីពីទីតាំងរកចំណីទៅទីតាំងបន្តពូជវិញនៅចន្លោះខែមេសានិងខែមិថុនា៕

# ការជួញដូរផ្លូវភេទរយៈពេល៦ខែឆ្នាំ២០២១ កើនឡើង១០០ករណី

*អត្ថបទ៖ ផល សុផានិត*

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២១ អាជ្ញាធរបានបង្ក្រាបបទល្មើសជួញដូរមនុស្សកើនឡើងជាង១០០ករណី បើប្រៀបធៀបនឹង៦ខែឆ្នាំមុន គឺមានតែ៦៣ករណី។ នេះបើតាមទំព័រហ្វេសប៊ុក សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ក្នុងប្រតិបត្តិការបង្ក្រាបការជួញដូរមនុស្សរយៈពេល៦ខែ ឆ្នាំ២០២១ មកនេះ អាជ្ញាធរបានបង្ក្រាប និងទប់ស្កាត់ករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ចំនួន១៩៨ករណី ដោយឃាត់ខ្លួនជនល្មើសចំនួន២៩១នាក់ និងបានរំដោះជនរងគ្រោះចំនួន៧២១នាក់។ តួលេខ៦ខែឆ្នាំនេះគឺកើនឡើងជាងពាក់កណ្តាល បើប្រៀបធៀបតួលេខ៦ខែឆ្នាំមុន គឺមានត្រឹមតែ៦៣ករណីឃាត់ខ្លួន២៩១នាក់ និងសង្គ្រោះជនរងគ្រោះចំនួន ៧២១នាក់។

បើតាមសម្តេច ស ខេង ការឈានដល់មានសកម្មភាពជួញដូរមនុស្សនេះ គឺកើតឡើងតាមរយៈអាពាហ៍ពិពាហ៍មិនស្របច្បាប់ទៅក្រៅប្រទេស ការធ្វើចំណាកស្រុកខុសច្បាប់ និងការប្រើឧបាយកលទុច្ចរិតអូសទាញ ឃោសនា ក្រោមរូបភាពផ្សេងទៀតរបស់ជនល្មើស។

សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ៦ខែនេះស្នងការដ្ឋាននគរបាលរាជធានីខេត្តបានល្បាតឃ្លាំមើល សកម្មភាពអាជីវកម្មផ្លូវភេទចំនួន១០២៧លើក នៅតាមគោលដៅ ចំនួន៣១៨ និងរកឃើញមនុស្សសរុបចំនួន១២៤៩នាក់ ក្នុងនោះស្រី១០៣៦នាក់។ ជាមួយគ្នានេះ អាជ្ញាធរខេត្តនីមួយៗក៏បានចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជួញដូរមនុស្សទៅ តាមគោលដៅដូចជាកន្លែងផ្តល់សេវាកម្សាន្តនានា។

ជាមួយគ្នានោះ អាជ្ញាធរក៏បានបង្ក្រាប និងទប់ស្កាត់ពលរដ្ឋខ្មែរ ដែលចំណាកស្រុកទៅធ្វើការខុសច្បាប់ នៅក្រៅប្រទេស បានចំនួន៨២លើក មនុស្សចំនួន៥៩៣នាក់ ក្នុងនោះមានស្ត្រី១៩៧នាក់។ ក្នុងចំណោមករណីនេះ គឺខេត្តបាត់ដំបងចំនួន៣០លើក ខេត្តកោះកុងចំនួន២៧លើក បន្ទាយមានជ័យចំនួន៨លើក តាកែវចំនួន៩លើក និងស្វាយរៀងចំនួន៥លើក។

បើតាមលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អ្នកចំណាកស្រុកទាំងនោះ គឺត្រូវបានអាជ្ញាធរណែនាំ និងឲ្យធ្វើកិច្ចសន្យា។ សម្តេច ស ខេង បានប្រាប់ឲ្យដឹងថា៖«ក្រោយពីបានទទួល និងឃាត់ខ្លួនពលរដ្ឋទាំងនោះ ក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឲ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត»។

ខណៈប្រតិបត្តិការបង្ក្រាបករណីជួញដូរមនុស្ស៦ខែនេះ ក៏មានពលករខ្មែរចំណាកស្រុកបានវិលត្រឡប់មកកម្ពុជាវិញសរុបចំនួន១៥០.៨៨៥នាក់ ដែលក្នុងនោះមានស្ត្រី៥៤.៥៥៦នាក់។ នេះបើតាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវឱ្យពលរដ្ឋចូលរួមរាយការណ៍ អំពីអំពើជួញដូរមនុស្សទៅអាជ្ញាធរ ក្នុងករណីពលរដ្ឋជួបបញ្ហានេះ ជាពិសេសចូលរួមណែនាំដល់ពលរដ្ឋដទៃទៀតអំពីបញ្ហានេះ៕

# ស្ពានអាកាសនិងផ្លូវក្រោមដីចោមចៅ សម្រេចបាន៧៩%

*អត្ថបទ៖ អរិយបុត្រ*

អ្នកទទួលខុសត្រូវការអនុវត្តការសាងសង់គម្រោងកសាងស្ពានអាកាសនិងផ្លូវក្រោមដីចោមចៅ បានអះអាងថា មកដល់ពេលនេះគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមួយនេះ ឈានទៅសម្រេចបានប្រមាណជាង៧៥ភាគរយហើយនៃគម្រោងសរុបជារួម។

លោក សំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញបានឲ្យដឹងនៅថ្ងៃទី១២ ខែសីហាថា គម្រោងស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ គិតមកដល់ថ្ងៃទី១២ សីហា សម្រេចបានប្រមាណជាង៧៥ភាគរយហើយ ខណៈស្ពានអាកាសនិងផ្លូវក្រោមដីនេះក៏ត្រូវបានបើកឱ្យដំណើរជាបណ្តោះអាសន្ននៃផ្នែកខ្លះហើយដែរ ដើម្បីសម្រួលចរាចរណ៍ជូនប្រជាពលរដ្ឋ។

ស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ ជាគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈរដ្ឋបាលរាជធានីភ្នំពេញ ទទួលម៉ៅការសាងសង់ដោយក្រុមហ៊ុនវិនិយោគទុនអនិកជនកម្ពុជា(OCIC) ដោយប្រើប្រាស់ការសាងសង់ក្នុងរយៈពេល៣០ខែ និងចំណាយថវិការសាងសង់ប្រមាណ២២លានដុល្លារអាមេរិក។

បន្ទាប់ពីបើកការដ្ឋានកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០កន្លងមកនេះ អាជ្ញាធររាជធានីបានប្រកាសដាក់ឲ្យដំណើរការផ្លូវក្រោមដីនៅរង្វង់មូលចោមចៅ ជូនប្រជាពលរដ្ឋបានធ្វើចរាចរណ៍ជាបណ្តោះអាសន្ន ហើយក្រោយពីដាក់ឲ្យដំណើរការផ្លូវក្រោមដីជូនប្រជាពលរដ្ឋបានធ្វើចរាចរណ៍ជាបណ្តោះអាសន្ន ឃើញថា ស្ថានភាពចរាចរណ៍ ពីផ្លូវជាតិលេខ៤ មកផ្លូវសហព័ន្ធរុស្ស៊ី មានលក្ខណៈល្អប្រសើរ។

ផ្លូវក្រោមដីនេះជាផ្លូវតភ្ជាប់ចរាចរណ៍ពីផ្លូវជាតិលេខ៤ មកមហាវិថីសហព័ន្ធរុស្ស៊ី មានប្រវែងសរុប ៤៧០ម៉ែត្រ ទទឹង៨,៥ម៉ែត្រ សម្រាប់ចរាចរណ៍មួយទិស ដែលមានពីរគន្លងរថយន្ត និងមួយគន្លងទោចក្រយានយន្ត ។ ការដ្ឋាននេះត្រូវសាងសង់ដោយបែងចែកជា៣ផ្នែកគឺ ស្ពានទី១ ជាស្ពានអាកាសមេតភ្ជាប់ចរាចរណ៍ ពីមហាវិថីសហព័ន្ធរុស្ស៊ី មកផ្លូវជាតិលេខ៣ មានប្រវែងសរុប ៤០៨ ម៉ែត្រ ទទឹង១៥,៨ម៉ែត្រ ដែលមានចរាចរណ៍ពីរគន្លងទៅនឹងពីរគន្លងមក ជម្រាលស្ពាន៤,៥ម៉ែត្រ និងមានកម្ពស់អតិបរមាដែលអាចចរាចរណ៍ក្រោមស្ពានមាន៥,៥ម៉ែត្រ។ ស្ពានទី២ បំបែកចេញពីស្ពានអាកាសមេ បត់ឆ្វេងតភ្ជាប់ចរាចរណ៍ពីមហាវិថីសហព័ន្ធរុស្ស៊ីឆ្ពោះទៅវេងស្រេង សម្រាប់ចរាចរមួយទិស ដែលមានមួយគន្លងរថយន្ត និងមួយគន្លងទោចក្រយានយន្ត មានប្រវែងសរុប២០២ម៉ែត្រ (ស្ពានអាកាសប្រវែង៤០ម៉ែត្រ ផ្លូវក្រោមដី ប្រវែង១១៨ម៉ែត្រនិងផ្លូវលើដីប្រវែង ៤៤ម៉ែត្រ) ទទឹង៥,២៥ម៉ែត្រ។

ស្ពានទី៣ ជាស្ពានកោងបត់ឆ្វេងតភ្ជាប់ចរាចរណ៍ពីផ្លូវវេងស្រេង មកផ្លូវជាតិលេខ៣ មានប្រវែងសរុប ២០៦ម៉ែត្រ (ស្ពានអាកាសប្រវែង៦០ម៉ែត្រ ផ្លូវក្រោមដីប្រវែង១១៨ម៉ែត្រ និងផ្លូវលើដីប្រវែង២៨ម៉ែត្រ) ទទឹង៥,២៥ម៉ែត្រ សម្រាប់ចរាចរណ៍មួយទិស ដែលមានមួយគន្លងរថយន្ត និងមួយគន្លងទោចក្រយានយន្ត។

ផ្លូវនិងផ្លូវក្រោមដី ជាផ្លូវកោង តភ្ជាប់ចរាចរពីផ្លូវវេងស្រេង មកផ្លូវជាតិលេខ៤ មានប្រវែងសរុប ១៣០ម៉ែត្រ (ផ្លូវក្រោមដី ប្រវែង១៣ម៉ែត្រ និងផ្លូវលើដីប្រវែង១១៧ម៉ែត្រ) ទទឹង៨,៥ម៉ែត្រ សម្រាប់ចរាចរណ៍មួយទិស ដែលមានពីរគន្លងរថយន្ត និងមួយគន្លងទោចក្រយានយន្ត។

ផ្លូវលើផ្ទៃដី ជាផ្លូវមេតភ្ជាប់ចរាចរណ៍ពីផ្លូវជាតិលេខ៤ មកផ្លូវវេងស្រេង មានប្រវែងសរុប ២៣៥ម៉ែត្រ ទទឹង៨,៥ម៉ែត្រ សម្រាប់ចរាចរណ៍មួយទិស ដែលមានពីរគន្លងរថយន្ត និងមួយគន្លងទោចក្រយានយន្ត។

ផ្លូវក្រោមដី ជាផ្លូវតភ្ជាប់ចរាចរណ៍ពីផ្លូវជាតិលេខ៤ មកមហាវិថីសហព័ន្ធរុស្ស៊ី ដែលមានប្រវែងសរុប ៤៧០ម៉ែត្រ ទទឹង៨,៥ម៉ែត្រ សម្រាប់ចរាចរណ៍មួយទិស ដែលមានពីរគន្លងរថយន្ត និងមួយគន្លងទោចក្រយានយន្ត។ ល្បឿនសុវត្ថិភាព ៤០គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ផ្លូវទទឹងទំហំ ទទឹង៨,៥ម៉ែត្រ ។ ល្បឿនសុវត្ថិភាព ២៥គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ផ្លូវទទឹងទំហំ ៥,២៥ម៉ែត្រ និងទំហំ៥,៥ម៉ែត្រ។

ស្ពាននឹងមានអាយុកាល១០០ឆ្នាំ មានបំពាក់បង្គោលភ្លើងបំភ្លឺផ្លូវ រៀបចំបណ្តាញជុំវិញបរិវេណស្ពានអាកាស និងអាងស្តុកទឹកក្រោមដី មានទាំងបំពាក់ម៉ូទ័របូមទឹកស្វ័យប្រវត្តិផងដែរ។ គួរបញ្ជាក់ទៀតថា ស្ពានអាកាស និងផ្លូវក្រោមដី នៅចំណុចរង្វង់មូលចោមចៅនេះ បានបើកការដ្ឋានដំណើរការសាងសង់ជាផ្លូវការកាលពីថ្ងៃទី២៩ មិថុនា ឆ្នាំ២០១៨ កន្លងមក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចតេជោហ៊ុនសែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា៕

# លោកស្រី ឱ វណ្ណឌីន៖ កុំព្រួយបារម្ភពីប្រតិកម្មក្រោយ ចាក់វ៉ាក់សាំងដូសជំរុញឬដូសទី៣

*អត្ថបទ៖ កែវ កញ្ញា*

លោកស្រី ឱ វណ្ណឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ១៩ ក្របខ័ណ្ឌទូទាំងប្រទេស បានអំពាវនាវដល់ប្រជាពលរដ្ឋកុំមានការព្រួយបារម្ភ ពីប្រតិកម្មក្រោយពេលចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣ ព្រោះដោយសារវ៉ាក់សាំងកំពុងធ្វើការជាមួយនឹងសរីរាង្គ។



លោកស្រីបានបញ្ជាក់ថា ជាទូទៅសម្រាប់ការចាក់វ៉ាក់សាំងគឺតែងតែមានប្រតិកម្មឆ្លើយតបរបស់វ៉ាក់សាំង គឺអាស្រ័យទៅ តាមប្រភេទនៃវ៉ាក់សាំងនីមួយៗ ហើយវ៉ាក់សាំងដែលគេធ្លាប់ផលិតតាមបែបបុរាណ ក៏មានប្រតិកម្មរបស់វាដែរ ព្រោះគ្រប់ប្រភេទវ៉ាក់សាំងគឺគេប្រើប្រាស់វីរុស ដើម្បីយកមកអនុវត្តផលិតជាវ៉ាក់សាំង ដូច្នេះប្រតិកម្មរបស់វ៉ាក់សាំងគឺត្រូវតែមាន។

លោកស្រីបានបន្តទៀតថា ការដែលមានប្រតិកម្មដូចជា ក្តៅខ្លួន ឈឺមួយចំហៀងខ្លួន ឈឺក្បាល ឈឺពោះ និងក្អួត ទាំងអស់នេះ គឺជាប្រតិកម្មធម្មតារបស់វ៉ាក់សាំងតែប៉ុណ្ណោះ។ លោកស្រីថា៖ «សូមបងប្អូនកុំមានការព្រួយបារម្ភអ្វី ហើយការដែលចេញរោគសញ្ញាអស់នេះ មានន័យថាវ៉ាក់សាំងកំពុងតែធ្វើការជាមួយសរីរាង្គរបស់យើង ហើយសរីរាង្គរបស់យើងក៏កំពុងតែធ្វើការជាមួយវ៉ាក់សាំងទៅវិញទៅមក»។

លោកស្រីបានបញ្ជាក់ថា វ៉ាក់សាំងដែលចាក់គឺជាឧបករណ៍មួយដែលជួយទៅដល់សរីរាង្គរបស់មនុស្ស ហើយបង្រៀនឱ្យកោសិកាមនុស្សទទួលយកនិងទទួលស្គាល់ថា ប្រសិនបើថ្ងៃក្រោយមានវីរុសប្រភេទហ្នឹងចូលមកក្នុងសរីរាង្គ អីចឹងកោសិកានឹងមានលទ្ធភាពតបតទៅមួយវីរុសហើយនៅ ពេលដែលវាបង្រៀនគ្នានេះ វានឹងធ្វើឱ្យយើងមានប្រតិកម្មមួយចំនួន។

លោកស្រីបន្ថែមថា ៖ «រោគសញ្ញាទាំងអស់នេះ វានឹងបាត់ទៅវិញ យ៉ាងយូរត្រឹមរយៈពេល ២ឬ៣ថ្ងៃ។ ប៉ុន្តែភាគច្រើនក្រុមការងារបានតាមដាន គឺត្រឹមតែ២ថ្ងៃទេ។ ហើយក្នុងរយៈពេល ២៤ ម៉ោងដំបូងគឺជាពេលវេលា ដែលវ៉ាក់សាំងកំពុងធ្វើការជាមួយគ្នាដែលធ្វើឱ្យមានប្រតិកម្ម ហើយបន្ទាប់ពីមួយថ្ងៃទៅ គឺស្ថានភាពមានការថយចុះហើយ។

លោកស្រីបានបញ្ជាក់ដែរថា បើសិនក្នុងករណីដែលប្រជាពលរដ្ឋចាក់វ៉ាក់សាំង ដូសទី៣រួចហើយ មានអាការៈថប់ដង្ហើមសូមប្រញាប់ទៅជួបជាមួយគ្រូពេទ្យ ព្រោះអាចមានករណីខ្លះ ដោយសារគាត់មានបញ្ហានៅក្នុងខ្លួនស្រាប់ ដូចនេះ នៅពេលដែលចាក់វ៉ាក់សាំងចូលទៅសរីរាង្គនឹងមានប្រតិកម្ម ប៉ុន្តែករណីទាំងនេះ គឺភាគតិចក្នុងចំណោម១លាននាក់ គឺអាចជួបត្រឹម២ឬ៣នាក់ ប៉ុណ្ណោះ៕

# WHO ផ្តល់ សម្ភារវេជ្ជសាស្ត្រ តម្លៃជាង៣២ ម៉ឺនដុល្លារ ដល់ រាជរដ្ឋាភិបាល កម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

តំណាងអង្គការសុខភាពពិភពលោក (WHO)ប្រចាំកម្ពុជា លោកស្រី លី អៃឡែន បានប្រគល់នូវសម្ភារវេជ្ជសាស្ត្រមួយចំនួនជូនរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសុខាភិបាល ដើម្បីប្រើប្រាស់ក្នុងការការពារទប់ស្កាត់ និងឆ្លើយតបការរាតត្បាតជំងឺកូវីដ-១៩ នាថ្ងៃទី២៤ខែសីហា នេះ នៅឃ្លាំងឱសថកណ្តាល នៃក្រសួងសុខាភិបាល។

ជំនួយជាឧបករណ៍សម្ភារបរិក្ខារវេជ្ជសាស្ត្រដែលអង្គការWHOផ្តល់ជូន រួមមាន៖

១) សម្ភារប្រព័ន្ធត្រជាក់ ដែលមានរថយន្តបំពាក់ប្រព័ន្ធត្រជាក់ធុនធ្ងន់សម្រាប់ដឹកវ៉ាក់សាំង ចំនួន ៣គ្រឿង និងបរិក្ខារបន្ទាប់បន្សំ។

២) សម្ភារបរិក្ខារវេជ្ជសាស្ត្រ មានម៉ាសចំនួន ១៦០,០០០ម៉ាស់ ស្រោមដៃចំនួន ១៦០,០០០ និងជែលលាងដៃ ចំនួន ៨,៧៥០ដប។

៣) សម្ភារអប់រំសុខភាព ចំនួន ៣០០,០០០ ដែលសរុបជាទឹកប្រាក់ចំនួន ៣២៨,០៧៦.៥០ដុល្លារអាមេរិក។

នាឱកាសនោះ លោកស្រី លី អៃឡែន បានសម្តែងនូវការកោតសរសើរ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសុខាភិបាល ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងប្រជាជនកម្ពុជាទាំងអស់ ដែលបានចូលរួមការពារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលរហូតមកដល់ពេលនេះស្ថានភាពនៃការរាលដាលព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ អាចគ្រប់គ្រងបាន។

លោកស្រី បានលើកឡើងថា អង្គការសុខភាពពិភពលោកនឹងនៅតែបន្តកិច្ចសហការ និងគាំទ្រវិស័យសុខាភិបាលកម្ពុជា មិនត្រឹមតែការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប៉ុណ្ណោះនេះ។

ចំណែកលោក ម៉ម ប៊ុនហេង ក៏បានថ្លែងអំណរគុណដល់អង្គការសុខភាពពិភពលោក ទាំងការិយាល័យនៅកម្ពុជា និងការិយាល័យប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច ដែលតែងតែជួយឧបត្ថម្ភគាំទ្រថវិកា និងបច្ចេកទេស ដល់វិស័យសុខាភិបាលកម្ពុជា។

លោកថា៖ «នេះសបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់ របស់អង្គការសុខភាពពិភពលោក ចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ជាពិសេសក្នុងកាលៈទេសៈបច្ចុប្បន្ន ដែលយើងបាននឹងកំពុងខិតខំប្រឹងប្រែងរួមគ្នា ដើម្បីជំរុញវិធានការការពារ ទប់ស្កាត់ និងឆ្លើយតបការរាតត្បាតនៃកូវីដ១៩ ឱ្យបានកាន់តែឆាប់រហ័ស»៕

# ទិវាសត្វដំរីពិភពលោកឆ្នាំនេះ «យើងរួមគ្នាការពារនិងអភិរក្សដំរីឱ្យបានគង់វង្ស»

*អត្ថបទ៖ អមរិន្ទ ដានុត*

សត្វដំរីអាស៊ីកំពុងរងការគំរាមកំហែងធ្ងន់ធ្ងរនៅទូទាំងដែនជម្រករបស់វា ទាំងក្នុងសកលលោក និងនៅកម្ពុជា ដោយសារតែនៅមានការបរបាញ់ ការដាក់អន្ទាក់ ជម្លោះរវាងមនុស្សនិងសត្វដំរី និងការចាប់ផ្សាំយកមកចិញ្ចឹមក្នុងស្រុក ដែលទាំងអស់នេះចាំបាច់ត្រូវរួមគ្នាចូលរួមការពារ និងអភិរក្សសត្វដំរីឱ្យបានគង់វង្ស។

នេះជាការលើកឡើងរបស់លោកនេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថានក្នុងឱកាសចូលរួមប្រារព្ធទិវាសត្វដំរីពិភពលោក ក្រោមប្រធានបទ ៖ «យើងរួមគ្នាការពារនិងអភិរក្សដំរីឱ្យបានគង់វង្ស»នៅថ្ងៃទី១២ ខែសីហានេះ។

លោកបានឱ្យដឹងថា រាជរដ្ឋាភិបាល បានអំពាវនាវឱ្យមានការចូលរួមកិច្ចការពារ និងអភិរក្សដំរីព្រៃនៅកម្ពុជា បន្ទាប់ពីទិន្នន័យពីម៉ាស៊ីនថតស្វ័យប្រវត្តិ ដែលត្រូវបានដាក់នៅក្នុងតំបន់ការពារធម្មជាតិនានា បានរកឃើញថា ដំរីអាស៊ីបានរស់នៅជាហ្វូងនៅក្នុងតំបន់ការពារធម្មជាតិរបស់កម្ពុជា ហើយមានឃើញកូនតូចៗជាច្រើនថែមទៀត។

លោកថា ៖ «បើទោះបីជាស្ថានភាពនៃការអភិរក្សតំបន់ការពារធម្មជាតិ មានភាពល្អ ប្រសើរក្នុងការផ្តល់ទីជម្រកប្រភពទឹក និងចំណីសម្រាប់សត្វដំរីរស់នៅ ប៉ុន្តែកត្តាគំរាមកំហែងមួយចំនួននៅតែមាន ជាពិសេសការរុករានទន្ទ្រានកាន់កាប់ដីព្រៃរដ្ឋខុសច្បាប់របស់ក្រុមជនខិលខូច ដែលបានប៉ះពាល់ដល់ទីជម្រករបស់សត្វដំរី និងកន្លែងដែលដំរីធ្លាប់រស់នៅ និងរក ចំណី និងប្រភពទឹក»។ អ្នកនាំពាក្យរូបនេះបានបន្ថែមថា ម្យ៉ាងទៀតគេក៏បានរកឃើញថា កូនដំរីព្រៃកំពុងទទួលរងការគំរាមកំហែងដោយសារតែការដាក់អន្ទាក់ និងការចាប់មកចិញ្ចឹម ខណៈការរេចរឹលនៃទីជម្រក បានធ្វើឱ្យដំរីអាស៊ីរស់នៅបែកខ្ញែកពីគ្នា និងបង្កជាឥទ្ធិពលអវិជ្ជមានដល់ស្ថិរភាពយូរអង្វែងរបស់ប្រភេទសត្វដ៏សំខាន់នេះ។

សត្វដំរីអាស៊ី ត្រូវបានចាត់បញ្ចូលជាប្រភេទជិតផុតពូជ នៅក្នុងបញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិ ដើម្បីការអភិរក្សធម្មជាតិ ហៅកាត់ IUCN ដែលត្រូវឱ្យមានការបញ្ឈប់សកម្មភាពទាំងឡាយ មានលក្ខណៈគំរាមកំហែងដល់ប្រភេទសត្វមួយនេះ។

ក្រសួងបរិស្ថាន ជាមួយអង្គការដៃគូ បានខិតខំរៀបចំផែនការសកម្មភាពដើម្បីអភិរក្សសត្វដំរីអាស៊ី ដោយនៅឆ្នាំ២០០៥ក្រុមអភិរក្សដំរីព្រៃនៅកម្ពុជា(CECG) ត្រូវបានបង្កើតឡើង ដើម្បីអភិរក្សដំរីអាស៊ីនៅកម្ពុជា តាមរយៈការរក្សាស្ថិរភាពនិងជំរុញឱ្យមានកំណើនចំនួនប្រភេទសត្វដំរី នៅក្នុងព្រៃនៃប្រទេសកម្ពុជា ហើយផែនការសកម្មភាពដើម្បីអភិរក្សសត្វដំរីអាស៊ីឱ្យនៅគង់វង្ស ត្រូវបាន រៀបចំឡើងសម្រាប់រយៈពេល១០ឆ្នាំ គឺចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៩ ដោយបានកំណត់នូវបញ្ហាអាទិភាពចំនួន៦ ក្នុងនោះរួមមាន៖ ការកាត់បន្ថយការបាត់បង់ទីជម្រក, អភិរក្សនិងតភ្ជាប់ច្រករបៀង និងហ្វូងដំរីព្រៃឡើងវិញ, ពង្រឹងការអនុវត្តន៍ច្បាប់, បង្ការមិនឱ្យមានការចាប់ដំរីព្រៃមកចិញ្ចឹម, បន្ធូរបន្ថយជម្លោះរវាងសត្វដំរីព្រៃនិងមនុស្ស, និងការអប់រំផ្សព្វផ្សាយ និងដាក់ចេញសកម្មភាពយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាទាំងនោះ។

បើតាមរបាយការណ៍របស់ក្រសួងបរិស្ថាន ដំរីអាស៊ីនៅកម្ពុជាមានចំនួនចន្លោះពី៤០០ទៅ៦០០ក្បាល ដែលភាគ ច្រើនរស់នៅក្នុងតំបន់ជួរភ្នំក្រវាញ តំបន់ខ្ពង់រាបខាងជើងទន្លេសាប និងតំបន់ខ្ពង់រាបភាគខាងកើត ក្នុងខេត្តមណ្ឌលគិរី ខេត្តរតនគិរី ដែលជាតំបន់ជីវៈចម្រុះសម្បូរបែបប្រព័ន្ធអេកូឡូស៊ី និងមានទីជម្រាលអំណោយផលដល់ការរស់នៅរបស់សត្វដំរី និងសត្វព្រៃផ្សេងៗទៀត។ ចំណែកដំរីស្រុកត្រូវបានប៉ាន់ស្មានថា មានប្រមាណជាង៧០ក្បាល។

យោងតាមការប៉ាន់ស្មានផែនការសកម្មភាពរយៈពេល១០ឆ្នាំ ដើម្បីអភិរក្សសត្វដំរីព្រៃអាស៊ី នេះត្រូវការថវិកាចំនួន៤០,៥លានដុល្លារអាមេរិក ដែលជាគម្រោងថវិការំពឹងថានឹងបានមកពីប្រភពរួមបញ្ចូលគ្នាទាំងកញ្ចប់ថវិការាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា៕







# ការបង្កបង្កើនផលដោយកម្លាំងសត្វពាហនៈនៅសល់ត្រឹម០,៨៤ភាគរយ

*អត្ថបទ៖ អរិយបុត្រ*

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានថ្លែងឲ្យដឹងថា សព្វថ្ងៃនេះការបង្កបង្កើនផលដោយកម្លាំងសត្វពាហនៈ គឺគោនិងក្របីគឺមានចំនួនត្រឹមតែប្រមាណជា ០,៨៤ភាគរយ ប៉ុណ្ណោះ ក្រៅពីនោះ គឺត្រូវបានប្រើប្រាស់ដោយកម្លាំងគ្រឿងយន្ត ។

លោក បានបញ្ជាក់ថា ៖ «បច្ចុប្បន្ន ក្រសួងបានសង្កេត ឃើញថាទាំងកសិករខ្នាតតូច មធ្យម និងក្រុមហ៊ុនវិនិយោគក្នុងវិស័យកសិកម្មភាគច្រើនបាន យល់ច្បាស់អំពីសារៈសំខាន់ និងប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍ និងគ្រឿងយន្តកសិកម្មលើផ្ទៃដីដែលមានវិសាលភាពល្វឹងល្វើយរបស់ពួកគាត់ ស្របពេលកង្វះកម្លាំងពលកម្មក្នុងវិស័យកសិកម្មផងនោះ ធ្វើឱ្យនិន្នាការនៃការប្រើប្រាស់ឧបករណ៍ និងគ្រឿងយន្តកសិកម្មមានការរីក ចម្រើនគួរឲ្យកត់សម្គាល់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ»។

លោកបានបន្តថា ស្របតាមនិន្នាការនេះ ការកសាង និងការពង្រឹងសមត្ថភាពកសិករអំពីការថែទាំ និងជួសជុលគ្រឿងយន្តកសិកម្ម គឺជារឿងចាំបាច់ ។

លោកបានបន្តថា ក្នុងទិសដៅជំរុញផលិតភាពអនុវិស័យដំណាំឱ្យកាន់តែរីកចម្រើនទាំងបរិមាណ និងគុណភាព ការបញ្ចូលយន្តូបនីយកម្មទៅក្នុងផលិតកម្មកសិកម្ម គឺភារកិច្ចអាទិភាពមួយដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការជំរុញធ្វើទំនើបកម្មកសិកម្មកម្ពុជា ដែលបាននិងកំពុងគិតគូ យកចិត្តទុកដាក់ ធ្វើយ៉ាងណាលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច ចំណេញពេល កាត់បន្ថយពលកម្ម ជំរុញល្បឿនផលិតកម្មកសិកម្ម តាមរយៈការប្រើប្រាស់គ្រឿងយន្តកសិកម្មសម្រាប់ភ្ជួររាស់ ដាំដុះ ស្ទូង ព្រោះ កម្ចាត់ស្មៅ ដឹកជញ្ជូន ច្រូត កាត់ បោកបែន សម្ងួត កិនស្រូវ និងកែច្នៃកសិផល។ល។



តាមស្ថិតិបានឲ្យដឹងថា ក្នុងឆ្នាំ២០២០ ស្ថិតិការងារភ្ជួររាស់ដីដាំដុះដំណាំស្រូវទូទាំងប្រទេសសម្រេចបានចំនួន ៣.៧៧៨.៣៤០ហត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មមានចំនួន ៣.៧៤៦.៦៨៩ហត ស្មើ៩៩,១៦% នៃផ្ទៃដីភ្ជួររាស់សរុប។ ផ្អែកតាមរបាយការណ៍របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត បានឱ្យដឹងថាស្ថិតិឧបករណ៍ និងគ្រឿងយន្តកសិកម្មទូទាំងប្រទេសមានចំនួនសរុបជាអាទិ៍ ត្រាក់ទ័រ ៣២.០៩៤គ្រឿង គោយន្ត ៤៩៨.១១៩គ្រឿង ម៉ាស៊ីនច្រូតស្រូវ ៦.៧៩២គ្រឿង ម៉ាស៊ីនបូមទឹក ៤០២.៧៩៦គ្រឿង ម៉ាស៊ីនបោកស្រូវ ១២.៥២៥ គ្រឿង និងម៉ាស៊ីនកិនស្រូវ ៤២ .៩៥៤គ្រឿង។ល។

លោកបានបន្តថា ព្រមជាមួយនឹងកំណើននៃការប្រើប្រាស់នេះ ជាលក្ខណបច្ចេកទេសនាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ជាទូទៅសង្កេតឃើញមានបញ្ហាមួយចំនួនបាននិងកំពុងកើតឡើងក្នុងមជ្ឈដ្ឋានកសិករដែលកំពុងប្រើប្រាស់គ្រឿងយន្តទាំងនោះ ដូចជា ៖ ការប្រើប្រាស់មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ការមើលថែរក្សា ជួសជុល ការយល់ដឹងអំពីមុខងាររបស់គ្រឿងយន្ត។ល។ កត្តាទាំងអស់នេះគឺជាដើមចមដ៏សំខាន់ធ្វើឱ្យគ្រឿងយន្តងាយរងការខូចខាតមុនអាយុកាលកំណត់ ខាតបង់ថវិកាសម្រាប់ធ្វើការជួសជុល ខាតបង់ពេលវេលាក្នុងការជួសជុល ខាតបង់ពេល វេលាក្នុងផលិតកម្ម និងបង្កើនការចំណាយ ដែលជះឥទ្ធិពលជាអវិជ្ជមានដល់ដើមទុនផលិតជារួម។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងក្នុងគោលបំណងដើម្បីជួយកាត់បន្ថយការចំណាយមិនសមស្របរបស់ប្រជាកសិករ និងដើម្បីឱ្យការប្រើប្រាស់គ្រឿងយន្តកសិកម្មមាន ប្រសិទ្ធភាពខ្ពស់ ស្របតាមបទដ្ឋានបច្ចេកទេស នាយកដ្ឋានវិស្វកម្មកសិកម្ម ដោយទទួលបានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី «ការប្រើប្រាស់ និងការថែទាំឧបករណ៍ និងគ្រឿងយន្តកសិកម្ម» ជូនដល់មន្ត្រីបច្ចេកទេស កសិករ និងអ្នកប្រើប្រាស់គ្រឿងយន្តកសិកម្មនៅតាមបណ្តាខេត្ត ក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងអំពីមូលដ្ឋានគ្រឹះនៃគ្រឿងយន្តកសិកម្ម ការថែរក្សា ការប្រើប្រាស់ ការជួសជុលបឋម... សំដៅកាត់បន្ថយការចំណាយទៅលើការជួសជុល ចំណេញពេលវេលា និងប្រើប្រាស់បានយូរអង្វែង៕

# កម្ពុជាផ្សព្វផ្សាយពីសក្តានុពលវិស័យទេសចរណ៍នៅទីផ្សារចិន

*អត្ថបទ៖ ស្រី និ*

ខណៈដែលមេរោគកូវីដ ១៩ នៅតែបន្តគំរាមកំហែងវិស័យទេសចរណ៍កម្ពុជា តំបន់ និងពិភពលោក ថ្មីៗនេះ ក្រសួងទេសចរណ៍កម្ពុជាសហការជាមួយក្រសួងការបរទេស និងស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំខេត្តសាន់ស៊ីបានចូលរួមពិព័រណ៍ទេសចរណ៍អន្តរជាតិវិថីសូត្រស៊ីអានលើកទី ៤ ឆ្នាំ២០២១ (XSRITE 2021) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦-១៨ ខែកក្កដា ឆ្នាំ២០២១ នៅស៊ីអានខេត្តសាន់ស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

កម្មវិធីនេះ ត្រូវបានគេដឹងថា មានការចូលរួមពីអ្នកទិញ អ្នកលក់ជាតិ និងអន្តរជាតិជាច្រើនដែលប្រមូលផ្តុំគ្នាទៅរួមមាន ស្តង់ពិព័រណ៍ចំនួន ៥០០ ស្តង់ អ្នកលក់ក្នុងស្រុកចំនួន ៣០០ និងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកចំនួន ៣។ ព្រឹត្តិការណ៍រយៈពេល ៣ ថ្ងៃនេះត្រូវបានគេរំពឹងថានឹងទទួលបានភ្ញៀវទេសចរជាង ២ ម៉ឺននាក់។

នៅក្នុងបណ្តាអ្នកចូលរួមតាំងពិពរណ៍នេះក៏មានស្តង់របស់ប្រទេសកម្ពុជាមានទំហំ ៥៤ម៉ែត្រការ៉េ សម្រាប់ផ្សព្វផ្សាយគោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិដ៏សម្បូរបែបរបស់កម្ពុជា។

ថ្មីៗនេះ ដោយមានការឯកភាពពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងទេសចរណ៍នឹងរៀបចំធ្វើជាម្ចាស់ផ្ទះវេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០២២ នៅខេត្តព្រះសីហនុ លើប្រធានបទ «អាស៊ាន - សហគមន៍សន្តិភាព និងវាសនារួមគ្នា» ដែលមានគោលបំណងដើម្បីស្តារ និងបើកឡើងវិញនៃវិស័យទេសចរណ៍ក្នុងតំបន់ឆ្ពោះទៅរកអនាគតប្រកបដោយនិរន្តរភាព និងទំនួលខុសត្រូវចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី២២ ខែមករា ឆ្នាំ២០២២ ។

ជាមួយគ្នានេះ ក្រសួងក៏បានប្រកាសអំពីការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី ៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០៥ ដល់ ១៧ ឧសភា និងថ្ងៃទី ០១ ដល់ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០២៣ នៅកម្ពុជា ប្រធានបទ «កីឡារស់ក្រោមសន្តិភាព»។

ប្រភពបានបន្តថា នៅថ្ងៃទី ១ នៃព្រឹត្តិការណ៍ពិព័រណ៍នេះ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាន់ស៊ីបានអញ្ជើញទស្សនាស្តង់ពិព័រណ៍ក្រសួងទេសចរណ៍កម្ពុជា ហើយបន្តទស្សនាការសម្តែងសិល្បៈនានាផងដែរ។

ក្រៅពីកម្ពុជា ប្រទេសជាសមាជិកអាស៊ានដែលបានចូលរួមជាភ្ញៀវអន្តរជាតិក្នុងការតាំងពិព័រណ៍នេះរួមមាន ប្រទេសថៃ ប្រទេសឥណ្ឌូនេស៊ី និងប្រទេសម៉ាឡេស៊ី៕

# ខេត្តសៀមរាប ក្លាយជាមណ្ឌលព្យាបាលជំងឺកូវីដ-១៩កម្រិតធ្ងន់ ក្នុងតំបន់ខាងជើងបឹងទន្លេសាប

*អត្ថបទ៖ ផល សុផានិត*

លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានលើកឡើងថា រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសុខាភិបាល បានសម្រេចយកខេត្តសៀមរាប ធ្វើជាមណ្ឌលព្យាបាលជំងឺកូវីដ-១៩ កម្រិតធ្ងន់ ថ្នាក់តំបន់ដែលមានវិសាលភាពលើខេត្តចំនួន៥ភាគខាងជើងបឹងទន្លេសាប។

លោកថ្លែងឡើងដូចនេះក្នុងឱកាសលោកចុះត្រួតពិនិត្យការរៀបចំទីតាំងសម្រាប់ព្យាបាលជំងឺកូវីដ៧១៩ និងមន្ទីរពិសោធន៍ថ្មី នៅក្នុងក្រុងសៀមរាប កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ ។

លោក ម៉ម ប៊ុនហេង បានមានប្រសាសន៍ថា៖ «ដើម្បីឆ្លើយតបនឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសុខាភិបាល បានសម្រេចយកខេត្តសៀមរាប ធ្វើជាមណ្ឌលព្យាបាលជំងឺកូវីដ-១៩ កម្រិតធ្ងន់ ថ្នាក់តំបន់ដែលមានវិសាលភាពលើខេត្តចំនួន៥ភាគខាងជើងបឹងទន្លេសាប»។

ខេត្តទាំង៥នោះ រួមមាន៖ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ដែលត្រូវបានរៀបចំឡើងនៅបរិវេណសាលមហោស្រពអង្គរ-កូអ៊ិច ស្ថិតនៅលស្ថិតក្នុងសង្កាត់ស្លក្រាម ក្រុងសៀមរាប ដែលទីតាំងនេះ អាចដាក់អ្នកជំងឺបានចំនួន៤០០នាក់។

លោកបានបន្ថែមទៀតថា តាមការពិតទៅនៅតាមបណ្តាខេត្តនានា សុទ្ធសឹងតែមានកន្លែងសម្រាប់ព្យាបាលអ្នកជំងឺកូវីដ-១៩ ដែលធ្ងន់ធ្ងរ ប៉ុន្តែ ការយកខេត្តសៀមរាបធ្វើជាមណ្ឌលព្យាលបាលអ្នកជំងឺកូវីដ-១៩ កម្រិតធ្ងន់នោះ វាសមស្របំផុត ដោយសារនៅខេត្តសៀមរាប មានមន្ទីរពិសោធន៍ថ្មី ដែលមានសមត្ថភាពអាចពិនិត្យសំណាកបានក្នុងមួយថ្ងៃជាង៩០០សំណាក និងឆាប់រហ័ស ដែលនេះជាការងាយស្រួលមួយក្នុងការព្យាបាលអ្នកជំងឺ។ លោក ម៉ម ប៊ុនហេងបានប្រាប់ថា មកដល់ពេលនេះ ក្រសួងបានកត់សម្គាល់ឃើញថា ស្ថានភាពឆ្លងជំងឺកូវីដ-១៩នៅកម្ពុជា កំពុងស្ថិតក្នុងនិន្នាការនៃការថយចុះ ក្រោយពីទទួលបាននូវលទ្ធផលចាក់វ៉ាក់សាំងនោះ តែទោះជាយ៉ាងនេះក្តី ការរៀបចំឲ្យមានមន្ទីរព្យាបាលកូវីដ-១៩ថ្មីបន្ថែមទៀត សម្រាប់ទទួលអ្នកជំងឺកំរិតធ្ងន់ថ្នាក់តំបន់នៅខេត្តសៀមរាបនោះ គឺជាយុទ្ធសាស្ត្រប្រៀបឈ្នះរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ លោករដ្ឋមន្ត្រីក្រសួងសុខាភិបាល បានអំពាវនាវចំពោះបងប្អូនប្រជាពលរដ្ឋទាំងអស់ទូទាំងប្រទេស បន្តប្រុងប្រយ័ត្នខ្ពស់ ដោយត្រូវចេះផ្លាស់ប្តូរទម្លាប់រស់នៅរបស់ខ្លួន រៀនរស់នៅធម្មតាជាមួយវុសកូវីដ-១៩ តាមបែបគន្លងថ្មី សំដៅបង្ការ គ្រប់គ្រង និងកាត់ផ្តាច់ខ្សែចម្លងវីរុសដ៏កាចសាហាវនេះ ជាពិសេស ពពួកប្រភេទបំប្លែងថ្មី ឬក៏ប្រភេទថ្មីៗផ្សេងទៀត៕

# ក្រសួងកសិកម្មស្នើឲ្យអ្នកដាំមៀនប៉ៃលិនបង្វែរទីផ្សារទៅកាន់ប្រទេស វៀតណាម និងជំរុញឲ្យពលរដ្ឋជួយទិញផលិតផលកសិកម្មនេះ

*អត្ថបទ៖ អរិយបុត្រ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា រដូវប្រមូលផលមៀនប៉ៃលិនកំពុងតែដំណើរការ ប៉ុន្តែដោយសារបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩ និងរបាំងភូតគាម អនាម័យ ជាកត្តាធ្វើឲ្យមានបញ្ហាប្រឈមមិនទាន់អាចធ្វើការនាំចេញទៅកាន់ទីផ្សារក្រៅប្រទេសបាន។

ក្រសួងថា ពិសេសប្រទេសថៃ ដែលកំពុងបិទមិនឲ្យនាំចូលមៀនប៉ៃលិនតាមច្រកព្រំដែន ហើយឆ្លើយតបនឹងបញ្ហានេះ ក្រសួងបានជំរុញស្នើឲ្យអ្នកដាំមៀនប៉ៃលិនបង្វែទីផ្សារទៅកាន់ប្រទេសវៀតណាម និង ជំរុញឲ្យពលរដ្ឋជួយទិញផលិតផលកសិកម្មនេះ ។

ក្រសួងកសិកម្មបានប្រកាសនៅថ្ងៃទី ១២ ខែសីហាថា ក្នុងគោលបំណងដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាទីផ្សារផលិតផលមៀនប៉ៃលិនដែលកំពុងជាប់ របាំងភូតគាមអនាម័យ និងបញ្ហាប្រឈមនានាបង្កឡើងដោយការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩ ក្រសួងកសិកម្ម អំពាវនាវដល់អ្នកនាំចេញគួរបង្វែរទិសដៅពីប្រទេសថៃទៅប្រទេសវៀតណាមវិញ ពីព្រោះកម្ពុជាចរចារអំពីបញ្ហា ផ្លែមៀននេះរួចហើយតាមរយៈការសម្រេចបាននូវការឯកភាពគ្នាលើលក្ខខណ្ឌតម្រូវភូតគាមអនាម័យជាមួយនឹងវៀតណាម។

ក្រសួងកសិកម្មក៏បានជំរុញឲ្យបងប្អូនប្រជាពលរដ្ឋគួររួមគ្នាគាំទ្រផលិតផលខ្មែរ ក្រោមរូបភាពខ្មែរជួយខ្មែរ ដោយជួយទិញផ្លែមៀនរបស់ប្រជាកសិករយើង ពិសេសសហគមន៍កសិកម្មមៀនប៉ៃលិននៅក្នុងកាលៈទេសៈដ៏លំបាកនេះ។

ក្រសួងក៏បានជំរុញឲ្យម្ចាស់ទីតាំងផ្សារទំនើប ក្រុមហ៊ុន ឬសិប្បកម្មកែច្នៃកសិផលក្នុងស្រុក គួរនាំគ្នាជួយប្រមូលទិញផ្លែមៀនប៉ៃលិន មកលក់ចែកចាយ ឬធ្វើការកែច្នៃសម្រាប់បម្រើដល់ការហូបចុកក្នុងស្រុកជំនួសឱ្យការនាំចូលនូវផ្លែមៀនកំប៉ុង ពីក្រៅប្រទេសវិញ។



> ផ្លែមៀនប៉ៃលិនជាប្រភេទទំនិញជាប់កម្រិតកំណត់ ដែលតម្រូវឱ្យសមត្ថកិច្ចភូកគាមអនាម័យ កម្ពុជា ធ្វើសំណើសុំចរចាបើកទីផ្សារជាមួយសមត្ថកិច្ចភូតគាមអនាម័យជាមួយនឹងប្រទេសនាំចូល តាមរយៈការស្នើសុំវាយតម្លៃហានិភ័យសមាសភាពចង្រៃ ពាក់ព័ន្ធនឹងការនាំចូលផ្លែមៀនប៉ៃលិននេះ

ប្រភពដដែលបានបន្តថា ផ្លែមៀនប៉ៃលិនជាប្រភេទទំនិញជាប់កម្រិតកំណត់ ដែលតម្រូវឱ្យសមត្ថកិច្ចភូកគាមអនាម័យ កម្ពុជា ធ្វើសំណើសុំចរចាបើកទីផ្សារជាមួយសមត្ថកិច្ចភូតគាមអនាម័យជាមួយនឹងប្រទេសនាំចូល តាមរយៈការស្នើសុំវាយតម្លៃហានិភ័យសមាសភាពចង្រៃ ពាក់ព័ន្ធនឹងការនាំចូលផ្លែមៀនប៉ៃលិននេះ។

ជាក់ស្តែង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់សំណើចរចាបើកទីផ្សារសម្រាប់ផ្លែមៀនស្រស់ទៅកាន់ ប្រទេសចិន និងប្រទេសថៃ រួចហើយ។

ប្រភពដដែលបានបន្តថា សម្រាប់ការចរចាជាមួយប្រទេសថៃ អគ្គនាយកដ្ឋានកសិកម្មជាសេនាធិការបច្ចេកទេស បានផ្ញើលិខិតចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៩ ដើម្បីស្នើសុំបើកទីផ្សារនាំចេញផ្លែមៀនកម្ពុជាទៅកាន់ប្រទេសថៃ ប៉ុន្តែរហូតមកដល់ពេល នេះ ការចរចាមិនទាន់សម្រេចបានលទ្ធផលឯកភាពគ្នា ស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចូលផ្លែមៀនទៅក្នុងប្រទេសថៃនៅឡើយទេ ហើយភាគីថៃក៏ពុំទាន់បានឆ្លើយតបជាផ្លូវការណាមួយដែរ ទោះបីជាភាគីកម្ពុជាបាន ទាក់ទងជំរុញការងារនេះជាច្រើនដងរួចហើយក៏ដោយ។

ប្រភពដដែលបានបន្តថា រីឯការចរចាជាមួយប្រទេសចិន អគ្គនាយកដ្ឋានកសិកម្មក៏បានផ្ញើលិខិតចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ដោយភ្ជាប់ជាមួយនូវឯកសារបច្ចេកទេសសម្រាប់ភាគីចិនធ្វើការវិភាគហានិភ័យសមាសភាពចង្រៃ ដើម្បីស្នើសុំបើកទីផ្សារនាំចេញ ផ្លែមៀនកម្ពុជាទៅកាន់ប្រទេសចិន។

ប្រភពដដែលបានបន្តថា ក្នុងបរិការណ៍នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ក៏បានអន្តរាគមន៍ទៅអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីពន្លឿនការចរចាស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញផ្លែមៀនស្រស់កម្ពុជាទៅកាន់ប្រទេស ចិនដែរ។ ប៉ុន្តែការចរចាមិនទាន់សម្រេចបានលទ្ធផលឯកភាពគ្នានៅឡើយ ដោយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិនកំពុងធ្វើការវិភាគហានិភ័យសមាសភាពចង្រៃស្របតាមវិធានបច្ចេកទេស និងបទដ្ឋានគតិយុត្តរបស់ប្រទេសចិន ដែលរហូតមកដល់ពេលនេះពុំទាន់បានទទួលការឆ្លើយតបជាផ្លូវការពាក់ព័ន្ធនឹងការងារបច្ចេកទេសនៅឡើយទេ៕

# អ្នករកស៊ីអនឡាញនឹងត្រូវផាកពិន័យនាពេលខាងមុខ

*អត្ថបទ៖ ផល សុផានិត*

លោក ប៉ែន សុវិជាតិ អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងពាណិជ្ជកម្មបានបញ្ជាក់ឲ្យដឹងថានាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម នឹងកំណត់កាលបរិច្ឆេទ ក្នុងការអនុវត្តច្បាប់ដើម្បីផាកពិន័យ ទៅដល់អ្នករកស៊ីតាមអនឡាញ ដែលមិនបានមកចុះបញ្ជីត្រឹមត្រូវជាមួយក្រសួង។

យោងសារព័ត៌មានក្នុងស្រុក ស្រង់សំដី លោក ប៉ែន សុវិជាតិ បានបញ្ជាក់យ៉ាងដូច្នេះថា «នាយកដ្ឋានចុះបញ្ជី នៃក្រសួងពាណិជ្ជកម្ម នឹងធ្វើសេចក្តីជូនដំណឹងថ្មី ដែលកំណត់ពីកាលបរិច្ឆេទក្នុងការអនុវត្តច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការផាកពិន័យ ក្នុងពេលវេលាសមស្របមួយ នាពេលខាងមុខ»។

លោក ប៉ែន សុវិជាតិ បានបញ្ជាក់ឲ្យដឹងថា មកទល់នឹងពេលបច្ចុប្បន្ននេះ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ពុំទាន់បានទទួលពាក្យស្នើសុំ លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកនៅឡើយទេ។

ជាមួយគ្នានេះ លោក ប៉ែន សុវិជាតិ ក៏បានឲ្យដឹងផងដែរថា ប៉ុន្តែនាយកដ្ឋានទទួលបានការសាកសួរព័ត៌មាន អំពីឯកសារតម្រូវនិងលក្ខខណ្ឌផ្សេងៗជាច្រើនដើម្បីធ្វើការដាក់ពាក្យស្នើសុំ។

មន្ត្រីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្មបានគូសបញ្ជាក់ថានាពេលយ៉ាងខ្លីខាងមុខនេះនឹងមានសហគ្រាសឯកបុគ្គលនិងក្រុមហ៊ុនជាច្រើនធ្វើការដាក់ពាក្យស្នើសុំបន្ទាប់ពីបានបំពេញពាក្យស្នើសុំនិងឯកសារតម្រូវគ្រប់គ្រាន់។ ប៉ុន្តែក្រសួងពាណិជ្ជកម្ម មិនទាន់ធ្វើការអនុវត្តការផាកពិន័យនេះ នៅឡើយទេ។

លោក ប៉ែន សុវិជាតិ បានលើកឡើងថា នាយកដ្ឋានចុះបញ្ជីកំពុងព្យាយាមធ្វើការផ្សព្វផ្សាយតាមរយៈសិក្ខាសាលាផ្សេងៗនិងទុកពេលវេលា ឲ្យសហគ្រាសឯកបុគ្គល និងក្រុមហ៊ុនមានការយល់ដឹង និងជ្រួតជ្រាបអំពីការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកនេះ។

គូសបញ្ជាក់ថាសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានរដ្ឋសភាអនុម័តជាស្ថាពរ ក្នុងសម័យប្រជុំពេញអង្គ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ។

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់វិធាន ជាមូលដ្ឋានដ៏សំខាន់ ក្នុងការជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុង និងក្រៅប្រទេសប្រកបដោយទំនុកចិត្ត តាមរយៈ ការទទួលស្គាល់សុពលភាព អានុភាព ភាពអាចអនុវត្តបាន និងភាពអាចទទួលយកបាន នៃទំនាក់ទំនងអេឡិចត្រូនិក កំណត់ត្រា អេឡិចត្រូនិក និងកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក ។ ព្រមទាំងមានការទទួលស្គាល់ថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិកដែលកំណត់ដោយបច្ចេកវិទ្យា និងគ្រប់គ្រងដោយស្ថាប័នរដ្ឋ។

សេចក្តីព្រាងច្បាប់នេះ នឹងរួមចំណែកយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចទីជីថលនៅកម្ពជា ដោយហេតុថា ក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តនានា ដែលគាំទ្រ ដល់សកម្មភាពនិងប្រតិបត្តិការ តាមប្រព័ន្ធអេឡិចត្រូនិក និងឌីជីថលចាំបាច់ត្រូវរៀបចំនិងធ្វើបច្ចុប្បន្នភាពដើម្បីអាចបង្កើតសេដ្ឋកិច្ចទីជីថលរឹងមាំមួយ ព្រមទាំងត្រៀមទទួលយក នូវការឈានមកដល់នៃបដិវត្តន៍ឧស្សាហកម្មទី។

ជាងនេះទៅទៀត សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់លទ្ធភាពឲ្យសហគ្រាសធុនតូច និងមធ្យម (SMEs) នៅកម្ពុជា អាចភ្ជាប់ខ្លួន នៅនឹងខ្សែសង្វាក់ផលិតកម្ម និងទីផ្សារក្នុងស្រុក និងអន្តរជាតិ ក៏ដូចជាជំរុញឲ្យមានការច្នៃប្រឌិត និងការបង្កើតទំនិញ និងសេវាថ្មីៗ បន្ថែមទៀតផងដែរ៕

# សិទ្ធិគ្រប់គ្រងព្រៃឈើ និងជលផល ផ្ដល់ប្រយោជន៍ដល់ប្រជាជនកម្ពុជារាប់ម៉ឺននាក់ និងអាចស្ដារជីវៈចម្រុះធម្មជាតិ







*អត្ថបទ៖ អមរិន្ទ ដានុត*

ប្រជាជនកម្ពុជានៅជនបទរាប់ម៉ឺននាក់ កំពុងពង្រឹងការអនុវត្តសិទ្ធិរបស់ពួកគេក្នុងការគ្រប់គ្រង ការពារ និងទទួលបានប្រយោជន៍ពីធនធានព្រៃឈើ និងជលផលនៅមូលដ្ឋានរបស់ពួកគេ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ទៅនឹងវិបត្តិ សេដ្ឋកិច្ច និងបរិស្ថាន។

លទ្ធផលខាងលើ សម្រេចទៅបាន ក៏ដោយមានការរួមចំណែកពីកម្មវិធីភាពជាដៃគូលើវិស័យព្រៃឈើ និងជលផលនៅកម្ពុជា ហៅកាត់ថា (PaFF) ដែលមានរយៈពេល៨ឆ្នាំ បែកចេញជាបីដំណាក់កាល។ ដំណាក់កាលទីបី នៃកម្មវិធីមានទឹកប្រាក់ចំនួន ៦,២ លានដុល្លារអាមេរិក នឹងធ្វើសិក្ខាសាលាផ្សព្វផ្សាយចាប់ផ្ដើមអនុវត្តន៍គម្រោងយមានការរច នៅរាជធានីភ្នំពេញ នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ។



PaFF ដំណាក់កាលទីបី បានទទួលមូលនិធិពីទីភ្នាក់ងារ សម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការប្រទេសស្វីស (SDC) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត (Sida)។ Sida ទើបចូលរួមផ្ដល់មូលនិធិនៅដំណាក់កាលទីបីនេះ ក្នុងគោលបំណងពង្រឹងដំណើរការប្រជាធិបតេយ្យ លើកកម្ពស់នីតិរដ្ឋ និងការពារសិទ្ធិរបស់ស្ត្រី ក្រុមជនជាតិដើមភាគតិច និងសមាជិកសហគមន៍ដែលមានប្រាក់ចំណូលទាប តាមរយៈការចូលរួមរបស់ពួកគេនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍។

កម្មវិធីPaFF ដំណាក់កាលទី៣ នឹងបន្តអនុវត្តន៍នៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដែលសម្របសម្រួលអនុវត្តដោយអង្គការចំនួន៤ គឺអង្គការ រីខូហ្វ (RECOFTC), អង្គការកម្មវិធីផ្លាស់ប្ដូរបទពិសោធន៍អនុផលព្រៃឈើនៅអាស៊ី (NTFP-EP), មូលនិធិសកលដើម្បីអភិរក្សធនធានធម្មជាតិ (WWF) និងសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA)។

PaFF ផ្ដោតលើការកសាងសមត្ថភាពដល់សហគមន៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីរដ្ឋាភិបាល ដើម្បីចូលរួមគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពតាមរយៈយន្តការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ដែលមាន សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ។

លោក សៀវ៉ា អនុប្រធានរដ្ឋបាលព្រៃឈើកម្ពុជា បានឱ្យដឹងថា គំនិតផ្ដួចផ្ដើមនេះ បានលើកកម្ពស់ជីវភាពរស់នៅ និងពង្រឹងសមត្ថភាពសហគមន៍ ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ លោកមានប្រសាសន៍ថា ៖ «យើងសូមសំដែងភាពត្រេកអរចំពោះសមិទ្ធផលរបស់កម្មវិធី PaFF នៅដំណាក់កាលទាំងពីរកន្លងមក និងរំពឹងថា PaFF ដំណាក់កាលទី៣ នឹងទទួលបានសមិទ្ធផលកាន់តែច្រើនបន្ថែមទៀត»។

ចំណែក លោក Markus Buerli នាយកនៃទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការប្រទេសស្វីស (SDC) ប្រចាំប្រទេសកម្ពុជា ក៏បានលើកឡើងដែរថា សមាជិកសហគមន៍នៅ ជនបទក្នុងប្រទេសកម្ពុជា មានសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលផ្សារភ្ជាប់ទៅនឹងនឹងធនធានធម្មជាតិ ដែលពួកគេពឹងអាស្រ័យសម្រាប់ជីវភាពរស់នៅ។

លោកថា នេះគឺជាមូលហេតុដែល PaFF អនុវត្តអភិក្រមដែលផ្ដោតលើលើសិទ្ធិស្របច្បាប់។ អភិក្រមនេះកំពុងតែជួយសហគមន៍ឲ្យមានសិទ្ធិទទួលបាន និងប្រើប្រាស់ធនធានព្រៃឈើ និងជលផលនៅមូលដ្ឋានរបស់ពួកគេ ស្របពេលជាមួយនឹងការលើកកម្ពស់ការយល់ដឹងដល់សហគមន៍ និងអាជ្ញាធរលើការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ដំណាក់កាលដំបូងទាំងពីររបស់ PaFF ចាប់ផ្ដើមពីខែវិច្ឆិកា ឆ្នាំ២០១៤ រហូតដល់ខែមិថុនា ឆ្នាំ២០២១ និងបានជួយដល់ប្រជាជនប្រមាណ ៤៤.៦០០ នាក់ ដែលពឹងផ្អែកលើព្រៃឈើ និងជលផលនៅក្នុងសហគមន៍ដើម្បីទ្រទង់ជីវភាពរស់នៅរបស់ពួកគេ។

ក្នុងដំណាក់កាលទាំងពីរនេះ PaFF បានជួយដល់សហគមន៍ចំនួន៦០ ឲ្យទទួលបានសិទ្ធិលើការគ្រប់គ្រងព្រៃឈើ និងជលផលក្នុងមូលដ្ឋានរបស់ពួកដោយផ្លូវការ និងបានគាំទ្រដល់សហគមន៍ចំនួន១៣៤ ក្នុងការអភិវឌ្ឍ និងអនុវត្តផែនការគ្រប់គ្រងធនធានទាំងនេះ។

ភាពជោគជ័យលើការអភិរក្សមួយចំនួនដែលបានពីការអនុវត្តកម្មវិធីមានដូចជា កំណត់ត្រាជាលើកដំបូងនៃការកើនឡើងចំនួនផ្សោត ១៥% ក្នុងឆ្នាំ២០១៧ បន្ទាប់ពីមានការធ្លាក់ចុះអស់២ទសវត្សរ៍។ ក្នុងតំបន់ទេសភាពមេគង្គ សត្វស្លាបដ៏កម្របំផុតនៅលើផែនដី គឺសត្វរំពេរទន្លេកើនចំនួនទ្វេរដងក្នុងរយៈពេល៥ឆ្នាំចុងក្រោយ និងមានកំណត់ត្រាបន្តបន្ទាប់នៃការកើនឡើងនូវចំនួនប្រភេទសត្វកំពុងរងគ្រោះថ្នាក់សំខាន់ៗ ដូចជា ត្រយ៉ងចង្កំកស និងសត្វត្មាតទាំងបីប្រភេទ។

នាយក អង្គការ WWF លោក សេង ទៀក ដែលបានដឹកនាំកម្មវិធីPaFF ២ ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ បានមានប្រសាសន៍ថា ៖ «ការរួមសហការគ្នារបស់អង្គការដៃគូនៃកម្មវិធីPaFF បង្ហាញឲ្យឃើញថា កិច្ចសហប្រតិបត្តិការ ធ្វើឲ្យការងារដំណើរការទៅបានល្អប្រសើរ និងទទួលបាននូវភាពជោគជ័យកាន់តែច្រើនសម្រាប់មនុស្ស និងធម្មជាតិ»។

លោកបានបន្ថែមទៀតថា ការពង្រឹងសមត្ថភាព និងផ្ដល់ធនធាននានាដែលសហគមន៍ត្រូវការ ដើម្បីឲ្យពួកគេអាចធ្វើការសម្រេចចិត្ត គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួន គឺជាតម្រូវការចាំបាច់សម្រាប់ការអនុវត្ត បន្តទៅមុខទៀត។

លោក សេង ទៀក បានឱ្យដឹងថា ៖ «ដើម្បីទទួលបានលទ្ធផលនេះ យើងត្រូវលើកកំពស់ភាពជាម្ចាស់ និងការគាំទ្រដល់ការអភិវឌ្ឍជីវភាពរស់នៅរយៈពេលវែង និងការអភិរក្សធនធានជីវៈចម្រុះ»។

ដំណាក់កាលចុងក្រោយរបស់កម្មវិធី PaFF នឹងពង្រឹងបន្ថែមទៅលើភាពជោគជ័យទាំងនេះ។ កម្មវិធីនឹងបន្តធ្វើតេស្តសាកល្បងនវានុវត្តន៍នានា ហើយស្របពេលជាមួយគ្នានោះ ក៏នឹងប្រើប្រាស់គម្រូអនុវត្ត និងពង្រីកឧត្តមានុវត្តន៍ទៅសហគមន៍ដទៃទៀតផងដែរ។

មុនពេលបញ្ចប់ដំណាក់កាលនេះ នៅខែមិថុនា ឆ្នាំ២០២៣ កម្មវិធីដៃគូនេះមានបំណងគាំទ្រដល់







ការអនុវត្តផែនការគ្រប់គ្រង សម្រាប់ព្រៃសហគមន៍ចំនួន ១១៣ កន្លែង ជលផលសហគមន៍ចំនួន ២៤ កន្លែង និងតំបន់ការពារនៅតាមសហគមន៍ចំនួន ៥ កន្លែង ដែលមានផ្ទៃដី សរុប ១៥៩.៧៦៧ ហិកតា និងផ្តល់ប្រយោជន៍ដល់ប្រជាជនចំនួន ៦០.៩២៦ នាក់ នៅក្នុង ២៤.៦៤៧ គ្រួសារចំពោះសិទ្ធិប្រើប្រាស់ប្រកបដោយចីរភាពរបស់ពួកគេ។

PaFF ក៏នឹងបន្តបង្កើតយន្តការហិរញ្ញប្បទានប្រកបដោយនិរន្តរភាព ដើម្បីឲ្យសហគមន៍អាចអនុវត្តផែនការគ្រប់គ្រងរបស់ពួកគេបាន។ ក្នុងដំណាក់កាលទី ៣ នេះ កម្មវិធីនឹងបង្កើតគម្រោងឥណទានសហគមន៍ព្រៃឈើចំនួន ១៤០ ដែលមានទុនសរុបចំនួន ៣៩២.០០០ ដុល្លារអាមេរិក និងមានសមាជិកចំនួន ១៧.០០០ គ្រួសារមានសិទ្ធិខ្ចីប្រាក់ ដែលរំពឹងថានឹងអាចវិភាជថវិការសម្រាប់គ្រងគ្រងសហគមន៍ចំនួន ២.៩៤០ ដុល្លារអាមេរិក ក្នុងមួយខែ។

កម្មវិធី ក៏នឹងបង្កើតបរធនខ្នាតតូចចំនួន ៧៦ ដែលមានទឹកប្រាក់សរុបចំនួន ៣៨០.០០០ ដុល្លារអាមេរិក។ កម្មវិធីនឹងបន្តគាំទ្រសហគ្រាសនៅតាមសហគមន៍ តាមរយៈកាផ្តល់ឱកាសវិនិយោគ ការធ្វើផែនការអាជីវកម្មដែលមានភាពល្អប្រសើរជាងមុន និងការភ្ជាប់ទំនាក់ទំនងរវាងផលិតករ និងទីផ្សារ។ សកម្មភាពទាំងនេះ ព្រមទាំងសកម្មភាពបង្កើតប្រាក់ចំណូលដទៃទៀត ដូចជា កសិរុក្ខកម្ម ឬចំការឈើដាំ គឺជាវិភាគទានដ៏សំខាន់ដែលបង្កលក្ខណៈឲ្យសហគមន៍អាចការពារ និងអនុវត្តផែនការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគេប្រកបដោយចីរភាព។

PaFF ក៏នឹងបន្តគាំទ្រដល់តំណាងរបស់សហគមន៍ ឲ្យចូលរួមយ៉ាងសកម្មក្នុងក្រុមការងារដើម្បីកំណែទម្រង់វិស័យព្រៃឈើ និងជលផលផងដែរ។ សកម្មភាពនេះធ្វើឲ្យសហគមន៍អាចចូលរួមជាមួយអាជ្ញាធរ និងស្វែងរកការគាំទ្រដើម្បីទទួលបានសិទ្ធិ និងផលប្រយោជន៍កាន់តែប្រសើរពីការគ្រប់គ្រងធនធានធម្មជាតិនៅកម្រិតមូលដ្ឋានរបស់ពួកគេ ។

លោកស្រី Camilla M Ottosson ប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃស្ថានទូតស៊ុយអែតប្រចាំនៅកម្ពុជា បានលើកឡើងថា ចំណុចខ្លាំងមួយរបស់ PaFF គឺការពង្រឹងសិទ្ធរបស់សមាជិកសហគមន៍ ដោយផ្តោតជាពិសេសលើជនជាតិដើមភាគតិច និងស្ត្រី ដើម្បីឲ្យពួកគេចូលរួមយ៉ាងសកម្មការពិភាក្សាអំពីការគ្រប់គ្រងធនធានធម្មជាតិ ការធ្វើផែនការអភិវឌ្ឍន៍ និងគោលនយោបាយ។

លោកស្រីមានប្រសាសន៍ថា ៖ «ចំណុចនេះគឺមានសារសំខាន់ណាស់សម្រាប់ការពង្រឹងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលចាំបាច់ ដើម្បីធានាលើសិទ្ធិដែលសហគមន៍មានលើធនធានធម្មជាតិ សម្រាប់ការគ្រប់គ្រងធនធានទាំងនោះនៅតាមសហគមន៍ប្រកបដោយចីរភាព»។

ក្នុងដំណាក់កាលចុងក្រោយនៃកម្មវិធី ដែលអង្គការរីខូហ្វ (RECOFTC) ជាអ្នកដឹកនាំ PaFF មានបំណងពង្រឹងបន្ថែមនូវគោលនយោបាយ និងក្របខណ្ឌច្បាប់ ដើម្បីការផ្តល់បរិយាប័ន្ន សមធម៌ និងប្រយោជន៍ចំពោះសហគមន៍នៅមូលដ្ឋាន ក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិកាន់តែប្រសើរ។

លោកស្រី ហូ កល្យាណ នាយិកាអង្គការរីខូហ្វ (RECOFTC) ប្រចាំប្រទេសកម្ពុជា បានឱ្យដឹងដែរថា នៅពេលដែលសហគមន៍មានសិទ្ធិលើធនធានធម្មជាតិរបស់ពួកគេហើយនោះ ធនធានទាំងនោះ ត្រូវបានគ្រប់គ្រងតាមវិធីដែលកាន់តែមានតម្លាភាព សុក្រឹតភាព គណនេយ្យភាព និងសមធម៌ ដែលនឹងឈានទៅមាននិរន្តរភាព។

លោកស្រីថា PaFF កំពុងតែធ្វើឲ្យសហគមន៍ដែលពឹងផ្អែកលើព្រៃឈើ និងជលផល អាចឆ្លើយតបបានកាន់តែប្រសើរទៅនឹងបញ្ហាប្រឈមដែលបង្កឡើងដោយកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័ស និងភាពវិចវិលនៃបរិស្ថាន។ តាមរយៈមធ្យោបាយផលិតកម្មដ៏រឹងមាំ គ្រួសារទាំងនេះនឹងមានប្រាក់ចំណូលចម្រុះពីធនធានធម្មជាតិ និងប្រភពស្បៀងអាហារផ្សេង។

ជាចុងក្រោយPaFF នឹងផ្តល់ប្រយោជន៍ដល់ប្រជាជនកម្ពុជានៅជនបទរាប់ម៉ឺននាក់ ស្របតាមគោលដៅដាក់ចុះក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា រួមមានការប្តេជ្ញាចិត្តអន្តរជាតិចំពោះការប្រែប្រួលអាកាសធាតុ និងជីវចម្រុះ និង វឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិផងដែរ៕

# រដ្ឋមន្ត្រីកសិកម្ម៖ ការបង្កបង្កើនផលនិង ការនាំចេញកសិផលកម្ពុជានៅតែប្រសើរ

*អត្ថបទ៖ អរិយបុត្រ*

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានអះអាងថា គិតមកត្រឹមថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២១ ការបង្កបង្កើនផលស្រូវ និងដំណាំរួមផ្សំនានា គឺកំពុងតែ ប្រព្រឹត្តទៅយ៉ាងល្អប្រសើរ រីឯការនាំចេញក៏ប្រសើរផងដែរ គ្រាន់តែបញ្ហារឿងអង្ករមានការ ធ្លាក់ចុះ ។

លោកវេង សាខុន បានអះអាងថា ការងារភ្ជួររាស់ដីមកដល់ពេលនេះកសិករទូទាំងប្រទេសសម្រេចបាន ២.៥៥០.៨៦៤ ហ.ត ស្មើនឹង ៩៧,៧៦% នៃផែនការ ២.៦០៩.០៦៥ ហ.ត ពោលគឺលឿនជាងឆ្នាំ២០២០ ចំនួន ៩៩.២៧៤ ហ.ត ក្នុងនោះ ការភ្ជួររាស់ដោយគ្រឿងយន្ត សម្រេចបាន ២.៥៣៥.០២២ ហ.ត ស្មើនឹង ៩៩,៣៨% ហើយការភ្ជួរដោយគោ/ក្របី មានចំនួន ១៥.៨៤២ ហ.ត ស្មើនឹង ០,៦២% ។

លោកបានបន្តថា លើការងារព្រួស និងស្ទូង គឺកសិករទូទាំងប្រទេសសម្រេច បានចំនួន ២.៤៥៣.២៩៤ ហ.ត ស្មើនឹង ៩៤,០៣% នៃផែនការ ២.៦០៩.០៦៥ ហ.ត លឿនជាងឆ្នាំ ២០២០ ចំនួន ១៦៦.១៣៦ ហ.ត, ក្នុងនោះ ស្រូវស្រាល សម្រេចបាន ៨៣៤.៧៣២ ហ.ត, ស្រូវ កណ្តាល ១.១៦៣.០៧៦ ហ.ត, ស្រូវធ្ងន់ ៤១៣.៣៩៦ ហ.ត, ស្រូវចំការ១៩.៤៤៤ ហ.ត, និង ស្រូវឡើងទឹកបាន២២.៦៤៦ ហ.ត ។

លោកបានបន្តទៀតថា បន្ទាប់ពីការងារដាំដុះ ការងារប្រមូលផលស្រូវរដូវវស្សានាពេលនេះសម្រេចបានជាបណ្តើៗមាន ចំនួន ១២៣.១៧៣ ហ.ត ស្មើនឹង ៥,០២% នៃផ្ទៃដីដែលបានអនុវត្តន៍សរុប ដែលក្នុងនេះទទួលបានទិន្នផលជាមធ្យមចំនួន ៤,០៨តោននៅក្នុងមួយហ.ត ជាមួយនឹងបរិមាណផលសរុបចំនួន ៥០៣.៥១៩ តោន ។

ក្រៅពីដំណាំស្រូវ គឺដំណាំសាកវប្បកម្ម ដែលជាប្រភេទដំណាំរួមផ្សំផ្សេងៗទៀត រយៈពេលខ្លីសម្រេចបានចំនួន ៤៨.២០៧ ហ.ត ស្មើនឹង ៨៧,៧០ % នៃផែនការ យឺតជាងឆ្នាំ២០២០ ចំនួន ១.៣៣៥ ហ.ត ដែលក្នុងនេះមានដំណាំសំខាន់ៗ ដូចជា ពោតសចំនួន ១១.៩៨២ ហ.ត, ដំឡូងផ្វាចំនួន ២.៥៣៤ ហ.ត និង បន្លែគ្រប់មុខចំនួន ៣០.៦៦៧ ហ.ត ។

លោករដ្ឋមន្ត្រីបានបន្តថា លើការដាំដុះដំណាំឧស្សាហកម្មរយៈពេលខ្លីសម្រេចបាន ៧៣១.៣០៧ ហ.ត ស្មើនឹង ៨៩,២២ % ។

លោកបានបញ្ជាក់ថា ដំណាំសំខាន់ៗដូចជា ពោត ក្រហមចំនួន ៧២.៧៣៦ ហ.ត, ដំឡូងមីចំនួន ៦០១.៣៤៦ ហ.ត, សណ្តែកបាយចំនួន ១៥.២៤៩ ហ.ត, សណ្តែកដីចំនួន ៥.៦៧៦ ហ.ត, សណ្តែកសៀងចំនួន ១២.២២៥ ហ.ត និងអំពៅចំនួន ១១.៣៨៥ ហ ត។

លោករដ្ឋមន្ត្រីបានបញ្ជាក់ថា៖ «ដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ ក្នុងរយៈពេល៧ខែឆ្នាំ២០២១នេះ កម្ពុជាបាននាំចេញកសិផលទៅក្រៅប្រទេសមាន បរិមាណសរុប ៥.០៣២.៩៦៨តោន ទៅកាន់ទិសដៅ ៦៤ប្រទេស គឺមានការកើនឡើង ៨៧,១០ភាគរយ»។

តាមរបាយការណ៍របស់ក្រសួងបានបង្ហាញថា បរិមាណអង្ករនាំចេញមានចំនួន ៣០៩.៨៦៥តោន មានការថយចុះ ២៧,២៧ភាគរយ បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៧ខែឆ្នាំ២០២០ ហើយការធ្លាក់ចុះនេះ ខាងសហព័ន្ធស្រូវអង្ករកម្ពុជាបានអះអាងថា វាមិនមែនបណ្តាលមកពី បញ្ហាទីផ្សារឬតម្លៃអង្ករកម្ពុជានោះទេ គឺដោយសារតែបញ្ហានៃការដឹកជញ្ជូន ដែលបង្ករដោយមេរោគកូវីដ ១៩ ។

របាយការណ៍បានឲ្យដឹងថា នៅក្នុងរយៈពេលនេះ កម្ពុជានាំចេញអង្ករក្រអូបគ្រប់ប្រភេទមានចំនួន២១៤.៩៦៨តោន ស្មើនឹង ៦៩,៣៧ភាគរយ អង្ករសគ្រប់ប្រភេទមានចំនួន ៨៨.៧០២តោន ស្មើនឹង ២៨,៦៣ភាគរយ និងអង្ករចំហុយមានចំនួន ៦.១៩៥តោន ស្មើនឹង ២ភាគរយ។ អង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២១ប្រទេស មានបរិមាណសរុបចំនួន ៧៧.៧៨៦តោន ថយចុះ ៤៦,០៧ភាគរយ ។ ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៥៣.៩២១តោន ថយចុះ ០,៩១ភាគរយ។ ទិសដៅអាស៊ានចំនួន ៥ប្រទេស មានបរិមាណសរុបចំនួន ២៩.៤៥៣តោនថយចុះ៤៨,៣៩ ភាគរយ និងទិសដៅដទៃទៀតចំនួន២២ប្រទេស មានបរិមាណសរុប ៤៨.៧០៥តោន ថយចុះ ២៩,៨៦ភាគរយ។

ទោះបីការកម្ពុជានាំចេញអង្ករថយចុះ ប៉ុន្តែលោក វេង សាខុន បានឲ្យដឹងថា ក្នុងរយៈពេល៧ខែឆ្នាំ២០២១ ការនាំចេញស្រូវមានចំនួន ២.០០៨.២៤១តោន នៅក្នុងនោះទៅកាន់ប្រទេសវៀតណាមដោយមានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១.២៩០.៥០២,៥២តោន ដែលមានការកើនឡើង ៨១,៣៤ភាគរយ។

លោកបានបន្តថា ក្នុងរយៈពេល៧ខែ ឆ្នាំ២០២១ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ មានចំនួន ៣.៤៣២.៦០១,០៨ តោនកើនឡើង ៥១,៦២ភាគរយ បើធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២០៕



# ស្ថាប័នពីរចុះហត្ថលេខាស្តីពី «ការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម»

*អត្ថបទ៖ អរិយបុត្រ*

នៅព្រឹកថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២១ អគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចុះអនុស្សារណៈយោគយល់គ្នាស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ហត្ថលេខីនៃអនុស្សារណៈនេះចុះដោយលោក ស្រី វុឌ្ឍី អគ្គលេខាធិការតំណាងឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយលោកស្រី សាយ សំអាត ជាប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា តំណាងឲ្យធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាព លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកស្រី អ៊ុក ម៉ាលី ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា និងមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួង និងធនាគារជាតិនៃកម្ពុជា រួមទាំង មន្ត្រីពាក់ព័ន្ធ។

លោកស្រី អ៊ុក ម៉ាលី បានមានប្រសាសន៍ថា ស្ថាប័នទាំងពីរនឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃនេះតទៅ ក្នុងគោលបំណងរួមគឺធ្វើការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងវិស័យកសិកម្ម។ លោក វេង សាខុន បានបញ្ជាក់ថា អនុស្សារណៈនេះរៀបចំឡើងដើម្បីបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរក្នុងការផ្លាស់ប្តូរព័ត៌មានឱ្យគ្នាទៅវិញ ទៅមកទាក់ទងទិន្នន័យ ការប្រឆាំង ការសម្អាតប្រាក់ហិរញ្ញប្បទាន ភេរវកម្មដែលប្រើប្រាស់ក្នុងវិស័យកសិកម្មមានជាអាទិ៍ ដូចជា បទល្មើសព្រៃឈើ បទល្មើសជលផល និងបទល្មើសផ្សេងៗទៀតតាមការចាំបាច់ដែលត្រូវបានសង្ស័យ ឬពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម។

មួយវិញទៀត អនុស្សរណៈនេះគឺមានបំណងពង្រឹង និងពង្រីកសមត្ថភាពរបស់មន្ត្រីក្នុងការវិភាគ តាមដាន និងត្រួតពិនិត្យរាល់សកម្មភាពរបស់ភេរវករក្នុងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រួចដាក់ចេញនូវយន្តការបង្ក្រាបឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រយោជន៍រក្សាបាននូវសន្តិសុខហិរញ្ញវត្ថុ បរិយាកាសនៃការវិនិយោគ ផ្តល់ភាពយុត្តិធម៌ សមធម៌ និងតម្លាភាពដល់វិនិយោគិន ឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣+២ ។

លោករដ្ឋមន្ត្រី បានបន្តទៀតថា អនុស្សរណៈនេះ នឹងផ្តល់ឱកាសឱ្យមន្ត្រីពាក់ព័ន្ធទទួលបានការបណ្តុះបណ្តាលបន្ថែមលើកម្រិតជំនាញស៊ើបការណ៍ហិរញ្ញវត្ថុពាក់ព័ន្ធនឹងបទល្មើស ការចែករំលែកព័ត៌មាន ទិន្នន័យបានទាន់ពេលវេលា មានភាពសុក្រឹត ពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយនេះ គឺជាយន្តការក្នុងការគ្រប់គ្រងវិបត្តិ និងហានិភ័យដែលអាចកើតឡើងក្នុងវិស័យហិរញ្ញវត្ថុ ធនាគារក្នុងវិស័យកសិកម្មក្នុងស្មារតីទទួលខុសត្រូវ៕

# កម្ពុជានឹងទទួលជំនួយហិរញ្ញវត្ថុ១,៥៦ពាន់លានដុល្លារ

*អត្ថបទ៖ អរិយបុត្រ*



ក្រុមប្រឹក្សាភិបាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ បានអនុម័តការបែងចែកថវិកាទូទៅមួយពីគណនីមូលនិធិពិសេស ជាប្រវត្តិសាស្ត្រ ដែលស្មើនឹង ៦៥០ ពាន់លានដុល្លារ ស.រ.អា កាលពីដើមខែសីហានេះ ដើម្បីជម្រុញលទ្ធភាពទូទាត់ការចំណាយរបស់សកលលោក នៅក្នុងនោះ អង្គការអុកស្វាមកម្ពុជាបានអះអាងថា កម្ពុជានឹងទទួលបានចំនួន ០,២៤% ឬប្រមាណជា ១,៥៦ ពាន់លាន ដុល្លារ។

លោកស្រី លីម សូលីន នាយិកាប្រចាំប្រទេសនៃអង្គការ អុកស្វាម មានប្រសាសន៍ថា ថវិកា SDRs ថ្មីនេះ នឹងជួយប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងកម្ពុជាផងដែរ ដើម្បីដោះស្រាយផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ។

លោកស្រីថា៖ «រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការងារយ៉ាងល្អដើម្បីទប់ស្កាត់ការចម្លងមេរោគនេះ ព្រមទាំងគាំទ្រក្រុមប្រជាជនងាយរងគ្រោះ ក្នុងការដោះស្រាយការបាត់បង់មុខរបររបស់ពួកគេ តាមរយៈការអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់ ដោយផ្អែកលើប្រព័ន្ធជំនួយសង្គមរបស់ខ្លួន»។

លោកស្រីលីម សូលីន បានបន្ថែមថា៖ «ទោះជាយ៉ាងណាក៏ដោយ នៅមានកិច្ចការចាំបាច់ជាច្រើនទៀតដែលគួរធ្វើ ហើយយើងសូមអំពាវឱ្យរាជរដ្ឋាភិបាលបន្តធ្វើការប្រកបដោយតម្លាភាព និងរួមគ្នាជាមួយអង្គការសង្គមស៊ីវិលដទៃទៀត ដើម្បីប្រើប្រាស់ហិរញ្ញប្បទានឥតសំណងបន្ថែមនេះឱ្យបានល្អបំផុត»។

ការផ្តល់អាទិភាពលើការថែទាំសុខភាពជាសកល និងការវិនិយោគលើកិច្ចគាំពារសង្គម ដែលអាចកាត់បន្ថយវិសមភាពដើម្បីសម្រេចបានការងើបឡើងវិញពីជំងឺរាតត្បាតជាសកលនេះប្រកបដោយលក្ខណ:ប្រកបដោយសមភាព និងកាន់តែមាននិរន្តរភាពថែមទៀត។ លោកស្រីបានបន្ថែម។

បច្ចុប្បន្ននេះ វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធតំណាងឱ្យ ៨៧,៥% នៃសេដ្ឋកិច្ចកម្ពុជា (យោងតាម ILO ២០២១) ហើយក្រសួងផែនការបានលើកឡើងថា កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ៦ លាននាក់ កំពុងប្រឈមនឹងការបាត់បង់មុខរបររបស់ពួកគេ នៅខណ:ពេលដែលជំងឺរាតត្បាតជាសកលនេះនៅតែបន្ត។

ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវធានាថាកម្មវិធីផ្តល់ជំនួយសង្គ្រោះរបស់ខ្លួន ផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគាំទ្រកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងអាជីវកម្មធុនតូច និងមធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា។

លោកស្រី លឹម សូលីន បានបន្ថែមទៀតថា៖ «យើងសូមកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានខិតខំប្រឹងប្រែងធានាថាក្រុមងាយរងគ្រោះនានាដូចជា ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាពាក់ព័ន្ធយេនឌ័រ ស្ត្រីមានផ្ទៃពោះ កុមារ ជនមានពិការភាព ជនជាតិដើម និងជនជាតិភាគតិច អ្នករស់នៅជាមួយមេរោគអេដស៍ ជនអនាថា និងជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់មកប្រទេសវិញ»។

លោកស្រីថា ពួកគេបានទទួលអត្ថប្រយោជន៍ពីកម្មវិធីជំនួយកូវីដ-១៩ ហើយលោកស្រីសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យទាញយកផលប្រយោជន៍ពីមូលនិធិ SDR នេះ ដើម្បីផ្តល់ការគាំទ្របន្ថែមទៀត និងធ្វើឱ្យអន្តរាគមន៍ឆ្លើយតបជំងឺរាតត្បាតមានលក្ខណ:បរិយាប័ន្ន។ ប្រជាជនកម្ពុជា ជាពិសេស ក្រុមងាយរងគ្រោះបំផុត នឹងចងចាំទុកក្នុងចិត្តនូវស្នាដៃដ៏សំខាន់នេះ។

SDRs គឺជាទម្រង់នៃរូបិយប័ណ្ណសកលមួយ ដែលអាចចាក់បញ្ចូលទៅក្នុងសេដ្ឋកិច្ចសកលលោក ដោយធ្វើការបែងចែកជំនួយដោយមិនចាំបាច់សងវិញ ជូនដល់ប្រទេសជាសមាជិកនីមួយៗរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ថវិកានេះមិនមែនជាកម្ចីដែលត្រូវការសងវិញនោះទេ ហើយការប្រើប្រាស់មូលនិធិនេះគឺជាការសម្រេចចិត្តដោយប្រទេសដែលទទួលមូលនិធិនេះ។ SDRs ថ្មីនេះ នឹងចូលជាធរមាននៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០២១ ។ ថវិកានេះត្រូវបានបែងចែកដោយផ្អែកលើកូតា/ចំណែករបស់ប្រទេសនីមួយៗនៅក្នុង IMF ។ ការផ្តល់ថវិកា SDR ចំនួន ៦៥០ ពាន់លានដុល្លារនេះ នឹងផ្តល់ប្រាក់បម្រុងបន្ថែមជិត ៤០០ ពាន់លានដុល្លារ ដល់ប្រទេសដែលមានជាងគេបំផុតក្នុងពិភពលោក, ២៣០ ពាន់លានដុល្លារ ដល់ប្រទេសដែលមានប្រាក់ចំណូលមធ្យម និង ២១ ពាន់លានដុល្លារ ដល់ប្រទេសដែលមានប្រាក់ចំណូលទាប៕

# សម្តេច ហេង សំរិន ទទួលតួនាទីជាប្រធានប្តូរវេន AIPA

*អត្ថបទ៖ ផល សុផានិត*




មហាសន្និបាតប្រចាំឆ្នាំ នៃអន្តរសភាអាស៊ាន ហៅកាត់ថា AIPA លើកទី៤២ ដែលសភាប្រទេសប៊្រុយណេ ធ្វើជាម្ចាស់ផ្ទះ បានបិទបញ្ចប់ដោយជោគជ័យនៅចុងខែសីហា ឆ្នាំ២០២១កន្លងមកនេះ ដោយនៅចុងបញ្ចប់នៃកម្មវិធីនេះ សម្តេច ហេង សំរិន ប្រធានរដ្ឋសភាកម្ពុជា បានទទួលធ្វើជាប្រធានមហាសន្និបាតប្រចាំឆ្នាំ នៃអន្តរសភាអាស៊ាន លើកទី៤៣ បន្តពីប្រទេសប៊្រុយណេរ។

សម្តេច ហេង សំរិន បានអបអរសាទរដល់ក្រុមប្រឹក្សានីតិប្បញ្ញត្តិនៃប្រទេសប្រុយណេ ដែលបានរៀបចំមហាសន្និបាតអាយប៉ាលើកទី៤២ ដោយជោគជ័យតាមប្រព័ន្ធវីដេអូ ខណ:ពេលដែលជំងឺរាតត្បាតកូវីដ-១៩ យ៉ាងណាក្តី។

ក្នុងនាមសភា នៃព្រះរាជាណាចក្រកម្ពុជា សម្តេច សូមទទួលយកការទទួលខុសត្រូវក្នុងនាមជាប្រធានអាយប៉ាប្តូរវេនពី លោក ប៉េហីន ដាតូ អាបឌុល រ៉ាម៉ាន ទីប។

សម្តេចបានជម្រាបគ្រួសារAIPA ថា មហាសន្និបាតអាយប៉ាលើកទី៤៣ ដែលសភានៃព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះ នឹងគ្រោងរៀបចំឡើងក្នុងខែកញ្ញា ឆ្នាំ២០២២ ។

សម្តេចបានគូសបញ្ជាក់ថា ដោយសារភាពមិនច្បាស់លាស់ ជុំវិញនៃការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ អាយប៉ានឹងជួបគ្នាតាមរយៈវិធីណាមួយ ដែលអាចធ្វើទៅបាន តែសម្តេចមានជំនឿថា មហាសន្និបាតលើកទី៤៣ គ្រួសារអាយប៉ាអាចនឹងជួបគ្នាដោយផ្ទាល់នៅលើទឹកដីដ៏បវរនៃព្រះរាជាណាចក្រកម្ពុជាដោយសារពេលនោះ ជំងឺកូវីដ-១៩ អាចនឹងត្រូវបានគ្រប់គ្រង និងសាបរលាបពីពិភពលោកនេះ។

ជាការកត់សម្គាល់ពីរឆ្នាំហើយដែល មហាសន្និបាតអាយប៉ារៀបចំតាមប្រព័ន្ធវីដេអូ ដោយសារការរាតត្បាតជំងឺកូវីដ១៩ ។អន្តរសភាអាស៊ាន (AIPA) ជាអង្គការអន្តរសភា តំណាងស្ថាប័ននីតិប្បញ្ញត្តិ នៃបណ្តាប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN) ដែលមាន ប្រទេសប៊្រុយណេកម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សឹង្ហបុរី ថៃ និងវៀតណាម។

វេទិកាសភានេះ ជាការប្រមូលផ្តុំសំឡេងប្រជាពលរដ្ឋក្នុងសហគមន៍អាស៊ាន ជាដៃគូរបស់អាស៊ាន ក្នុងការជំរុញឱ្យសម្រេចបាននូវគោលដៅសហគមន៍អាស៊ានតែមួយ។ អន្តរសភាអាស៊ាន រៀបចំមហាសន្និបាតប្រចាំឆ្នាំ នៅរៀងរាល់ឆ្នាំ ដោយប្រទេសជាសមាជិកប្តូរវេន រៀបចំតាមលំដាប់អក្ខរក្រម នៃឈ្មោះប្រទេសតាមអក្សរឡាតាំង។

ក្នុងឋាន:ជាប្រធានអាយប៉ាលើកទី៤៣ សម្តេច ហេង សំរិន បានគូសបញ្ជាក់ថា សភាកម្ពុជារង់ចាំធ្វើការយ៉ាងជិតស្និទ្ធជាមួយ លេខាធិការដ្ឋានអាយប៉ា ក៏ដូចជាសភាសមាជិកអាយប៉ា ព្រមទាំងបណ្តាប្រទេសជាដៃគូរនានា ដើម្បីបន្តពង្រឹងការងារល្អរបស់យើង និងធានាឱ្យសម្រេចបាននូវចក្ខុវិស័យ និងសេចក្តីប្រាថ្នារួមរបស់អាស៊ាន ជាពិសេស ការសម្រេចឱ្យបាននូវសហគមន៍អាស៊ានដែលផ្តោតលើប្រជាជន និងមានប្រជាជនជាស្នូល៕

# កិច្ចប្រជុំមេគង្គ-គង្គាឯកភាព លើការពិភាក្សា ដើម្បីស្វែងរក ដំណោះស្រាយស្តារសេដ្ឋកិច្ចសង្គម

*អត្ថបទ៖ ផល សុផានិត*

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ឧបនាយករដ្ឋមន្រ្តី ប្រាក់ សុខុន រដ្ឋមន្រ្តីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំរដ្ឋមន្រ្តីការបរ ទេសមេគង្គ-គង្គាលើកទី១១ ជាមួយ បណ្ឌិត ស៊ូប្រាម៉ានយ៉ាំ ចៃហ្សានកា រដ្ឋមន្រ្តីការបរទេស នៃសាធារណរដ្ឋឥណ្ឌា តាមប្រព័ន្ធវីដេអូ និងមានការអញ្ជើញចូលរួមរបស់រដ្ឋមន្រ្តីការបរទេសនៃបណ្តាប្រទេសជាសមាជិកមេគង្គ ដទៃទៀត។



បើតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចេញនៅយប់ថ្ងៃទី២១ ខែកក្កដា។ ប្រភពដដែលបន្តថា នាឱកាសគម្រប់ខួបអនុស្សាវរីយ៍ ២០ឆ្នាំ នៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា(២០០០-២០២០) រដ្ឋមន្រ្តីទាំងអស់ បានថ្លែងកោតសរសើរចំពោះវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរយៈពេល៤ឆ្នាំ នៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា ២០១៩-២០២២ ។

កិច្ចប្រជុំ ក៏បើកសម្ពោធឱ្យដំណើរការនូវគេហទំព័រ MGC និងការចាក់បង្ហាញឯកសារវីដេអូដែលឆ្លុះបញ្ចាំងអំពីសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការ ក៏ដូចជាធនធានធម្មជាតិ សង្គម និងវប្បធម៌ដ៏សម្បូរបែបរបស់ប្រទេសសមាជិក។

គួរបញ្ជាក់ផងដែរថា ជំងឺរាតត្បាតកូវីដ-១៩ បានពន្យារពេលដល់ការប្រារព្ធខួបអនុស្សាវរីយ៍២០ឆ្នាំ នៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា ដែលបានគ្រោងរៀបចំនៅខែមេសា ឆ្នាំ២០២០ នៅសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ខេត្តសៀមរាប ប្រទេសកម្ពុជា។

រដ្ឋមន្រ្តីទាំងអស់បានសម្តែងក្តីសង្ឃឹមថា នឹងអាចរៀបចំព្រឹត្តិការណ៍អបអរសាទរក្នុងពេលឆាប់ៗខាងមុខ នៅពេលដែលស្ថានភាពជំងឺរាតត្បាតកូវីដ-១៩ មានភាពប្រសើរឡើង។

រដ្ឋមន្រ្តីទាំងអស់បានកោតសរសើរចំពោះការគាំទ្រគ្នាទៅវិញទៅមករវាងបណ្តាប្រទេសមេគង្គ-គង្គា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ ។

ដោយយល់ច្បាស់អំពីបញ្ហាប្រឈមដែលបង្កឡើងដោយជំងឺរាតត្បាតកូវីដ-១៩ រដ្ឋមន្រ្តីទាំងអស់បានឯកភាពលើការធ្វើសិក្ខាសា លាជាក់ស្តែង ដើម្បីឆ្ពោះទៅរកការពន្លឿនដំណើរការនៃការស្តារសេដ្ឋកិច្ចសង្គម ក្រោយការរីករាលដាលជំងឺកូវីដ-១៩ ក៏ដូចជាការជំរុញការផ្លាស់ប្តូរគំនិត ស្តីពីវិធីលើកកម្ពស់សុខភាពសាធារណៈ និងធានាបាននូវសន្តិសុខសុខភាពក្នុងយុគសម័យក្រោយការរាតត្បាតកូវីដ-១៩ ជាពិសេសការអភិវឌ្ឍការស្រាវ ជ្រាវវេជ្ជសាស្រ្ត ការផលិត ការចែកចាយថ្នាំ និងវ៉ាក់សាំង។ រដ្ឋមន្រ្តីទាំងអស់បានស្វាគមន៍ជំនួយរបស់ឥណ្ឌាដល់បណ្តាប្រទេសមេគង្គ ក្រោមគម្រោងទទួលផលរហ័ស(Quick Impact Projects) នៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា និងបានកត់សម្គាល់ថា ចាប់តាំងពីការចាប់ផ្តើមរបស់ខ្លួននៅក្នុងឆ្នាំ២០១៥ គម្រោងចំនួន៣៨ បានបញ្ចប់ និង ៣០គម្រោងផ្សេងទៀតកំពុងអនុវត្ត។

ក្នុងឱកាសនៃកិច្ចប្រជុំនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា អស់រយៈពេលពីរទសវត្សរ៍កន្លងមកនេះ គម្រោង និងសកម្មភាពជាច្រើនក្រោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា បា នចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍនៅក្នុងអនុតំបន់មេគង្គ រួមមានវិស័យសុខាភិបាល អប់រំ បរិស្ថាន និងវប្បធម៌។



ព្រមជាមួយគ្នានេះដែរ កិច្ចសហប្រតិបត្តិការមេគង្គ-គង្គា បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ទំនាក់ទំនងជិតស្និទ្ធ ការយោគយល់ និងការជឿទុកចិត្តគ្នា ព្រមទាំងបានលើកកម្ព ស់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៅក្នុងអនុតំបន់មេគង្គ ដើម្បីឈានទៅសម្រេចឱ្យបាននូវសុខុមាលភាព និងវិបុលភាព សម្រាប់ប្រជាជននៃប្រទេសសមាជិក។

ឧបនាយករដ្ឋមន្រ្តី បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការប្តេជ្ញាចិត្តច្បាស់លាស់របស់ប្រទេសឥណ្ឌា ក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងទទួលផលរហ័ស ចំពោះប្រទេសកម្ពុជា និងប្រទេសមេគង្គដទៃទៀត ដោយបាននាំមកនូវលទ្ធផលជា ក់ស្តែងជាច្រើន ដែលរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងអនុតំបន់មេគង្គ និងបានថ្លែងអំណរគុណផងដែរ ចំពោះប្រទេសឥណ្ឌា ដែលបានបង្កើននូវការផ្តល់ជំនួយសម្រាប់គម្រោងទទួលផលរហ័សដល់កម្ពុជា។

លោកឧបនាយករដ្ឋមន្រ្តីបានការគាំទ្រ និងវាយតម្លៃខ្ពស់ ចំពោះសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ដែលបានបង្កើតឡើងក្នុងឆ្នាំ២០១៤ នៅខេត្តសៀមរាប ដែលជាសមិទ្ធផលមួយដែលឆ្លុះបញ្ចាំងអំពីសារៈសំខាន់ និងនិរន្តរភាព នៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា។

ជាអកុសល ឧស្សាហកម្មទេសចរណ៍ត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំងដោយជំងឺរាតត្បាតកូវីដ-១៩ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់សារមន្ទីរ។ ក្នុងន័យនេះ មានតែផែនការស្តារឡើងវិញរបស់សារមន្ទីរ ដែលមានការគាំទ្រពីបណ្តាប្រទេសជាសមាជិកតែប៉ុណ្ណោះ ទើបអាចដោះស្រាយនូវរាល់បញ្ហាប្រឈមនានា ហើយអាចឈានទៅរកភាពប្រក្រតីជាថ្មីឡើងវិញ៕

## គណៈកម្មការអន្តរក្រសួង៖ បង្កើនឱកាសការងារ និងអភិចាលកិច្ចទីផ្សារ លើកកម្ពស់ជំនាញវិជ្ជាជីវៈ

*អត្ថបទ៖ អមរិន្ទ ដានុត*

គណៈកម្មការអន្តរ ក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ បានបើកកិច្ចប្រជុំមួយកាលពីខែសីហាកន្លងមកនេះ ដែលមានការចូលរួមពីសំណាក់តំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងគោលបំណងពិនិត្យ និងវាយតម្លៃពីវឌ្ឍនៈភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ និងបញ្ហាប្រឈមនៅក្នុងបរិបទជំងឺកូវីដ-១៩ ។

លោកអិត សំហេង លោកអិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការអន្តរក្រសួងនេះ បានដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ ដោយបានវាយតំលៃខ្ពស់ចំពោះសមិទ្ធផលសម្រេចបាននាពេលកន្លងមក។

លោកក៏បានស្នើសុំថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរដ្ឋបាលរាជធានី-ខេត្ត វិស័យឯកជនបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការចូលរួមអនុវត្តគោលនយោបាយនេះដើម្បីធ្វើការផ្លាស់ប្តូរ និងលើកស្ទួយរចនាសម្ព័នឧស្សាកម្ម ពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មពលកម្មផ្អែកលើជំនាញនៅឆ្នាំ២០២៥ ក៏ដូចជាការលើកកម្ពស់ការប្រកួតប្រជែង និងផលិតភាព សំដៅប្រែក្លាយពីឧស្សាហកម្មមានតម្លៃបន្ថែមទាប ទៅជាឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ផងដែរ។

លោកថា ៖«ការប្រែក្លាយនេះឱ្យស្របតាមគោលនយោបាយជាតិអភិវឌ្ឍន៏វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ និងចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានកំណើនខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន សម្រាប់ភាពសុខដុមក្នុងសង្គមដោយផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសការងារសមរម្យ និងប្រកបដោយផលិតភាពការងារខ្ពស់ ស្របតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល»៕

# កម្ពុជាមានគោលនយោបាយចាក់វ៉ាក់សាំងបង្ការកូវីដ១៩ដូសជំរុញ







*អត្ថបទ៖ អមរិន្ទ ដានុត*

ដើម្បីត្រៀម លក្ខណៈឈានឆ្ពោះទៅកាន់ផែនការនៃការបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ និង ការរស់នៅជាមួយនឹងវត្តមានជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី រាជរដ្ឋាភិបាលសម្រេចប្រកាសដាក់ចេញ នូវ «គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ» ដល់ប្រជាជនទូទៅចាប់ពីអាយុ ១២ ឆ្នាំឡើងទៅ ចាប់ពីខែសីហា ឆ្នាំ២០២១ នេះ ដល់អំឡុងពាក់កណ្ដាលឆ្នាំ ២០២២ ។

យោងតាមសេចក្ដីប្រកាសស្ដីពីគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ដែលចេញដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នាពថ្ងៃទី២៥ ខែសីហា នេះ បានលើកឡើងថា ទឡ្ហីករណ៍បែបវិទ្យាសាស្ត្រដែលបានលើកឡើងនៅក្នុងឯកសារសិក្សាស្រាវជ្រាវពីប្រទេសជាច្រើន បានបង្ហាញថាក្រោយពេលចាក់វ៉ាក់សាំងមូលដ្ឋានគ្រប់ដូសរួចហើយ, កម្រិតភាពស៊ាំប្រឆាំងនឹងមេរោគកូវីដ-១៩ អាចស្ថិតនៅរយៈពេលប្រមាណពី ៦ ទៅ ៨ ខែ សម្រាប់ករណីទូទៅនិងអាចខ្លីជាងនេះសម្រាប់ក្រុមមនុស្សវ័យចាស់ និងអ្នកមានប្រព័ន្ធការពារខ្សោយ។

សេចក្ដីប្រកាសបានបន្តថា ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ អាចបង្កើនភាពឆ្លើយតបនៃអង្គបដិបក្ខនៃប្រព័ន្ធការពារក្នុងខ្លួន ឱ្យកាន់តែប្រសើរឡើង ថែមទៀត ដើម្បីប្រឆាំងនឹងមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត។

ផ្អែកលើទឡ្ហីករណ៍វិទ្យាសាស្ត្រខាងលើនេះ និងយោងតាមប្រភពព័ត៌មានដែលផ្សព្វផ្សាយជាសាធារណៈ ប្រទេស ជាច្រើនរួមមាន អ៊ីស្រាអែល, សហរដ្ឋអាមេរិក, ហុងគ្រី, ឥណ្ឌូនេស៊ី, អារ៉ាប់អេមីរ៉ាត, រុស្ស៊ី, ឈីលី, បារាំង, អង់គ្លេស, អាល្លឺម៉ង់, អូទ្រីស ជាដើម បានសម្រេចចិត្ត ឬគ្រោងចាក់វ៉ាក់សាំងដូសជំរុញនេះ ដើម្បីទប់ទល់ជាមួយនឹងការវាយលុកទ្រង់ទ្រាយធំនៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មី ផ្សេងទៀត។

សម្រាប់ប្រទេសកម្ពុជា, ទន្ទឹមនឹងការសម្រេចប្រើប្រាស់វ៉ាក់សាំងប្រភេទ AstraZeneca ដើម្បីចាក់ជាដូសជំរុញដល់មន្ត្រីសុខាភិបាល និងមន្ត្រីបម្រើការជួរមុខក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅតាម តំបន់ដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) កាលពីដើមខែ សីហា ឆ្នាំ២០២១ កន្លងទៅ។

ក្រុមការងារជំនាញក៏បានសិក្សាស្រាវជ្រាវរកឃើញដែរថា ការចាក់ដូសជំរុញនេះ ទោះបីប្រើប្រាស់វ៉ាក់សាំងប្រភេទដូចគ្នា ឬវ៉ាក់សាំងប្រភេទខុសគ្នាក៏ដោយ មិនបង្កឱ្យមានផលរំខានច្រើនលើស ពីផលរំខានដែលបង្កឡើងដោយវ៉ាក់សាំងនីមួយៗជាធម្មតានោះទេ ហើយការចាក់ដូសជំរុញនេះថែមទាំងអាច បង្កើនបាននូវប្រព័ន្ធការពាររាងកាយកាន់តែរឹងមាំ ក្នុងការទប់ទល់នឹងមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត។

សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់នៅក្នុងសេចក្ដីប្រកាសនេះថា ការចាក់វ៉ាក់សាំងកូវីដ-១៩ ជំរុញនេះ គឺអនុវត្តតាមគោលការណ៍ស្ម័គ្រចិត្ត។ រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តគោលការណ៍ស្ម័គ្រចិត្តដដែល ចំពោះការចាក់វ៉ាក់សាំងដូសជំរុញនេះជូនដល់ប្រជាជន។

សម្ដេចថា៖ «រាជរដ្ឋាភិបាលក៏បន្តលើកទឹកចិត្តដល់ប្រជាជន ដែលមានលក្ខណៈសម្បត្តិសមស្របតាមលក្ខខណ្ឌបច្ចេកទេសដែលបានចាក់វ៉ាក់សាំងជុំទី១ រួច មកទទួលយក វ៉ាក់សាំងដូសជំរុញនេះឱ្យបានគ្រប់ៗគ្នា ដើម្បីជួយបង្កើនភាពឆ្លើយតបនៃអង្គបដិបក្ខនៃប្រព័ន្ធការពារក្នុងខ្លួន ឱ្យកាន់តែប្រសើរឡើងប្រឆាំងនឹងមេរោគកូវីដ-១៩ ជាពិសេស ទប់ទល់នឹងមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត ដើម្បីការពារអាយុជីវិតខ្លួនឯង និងក្រុមគ្រួសារ ព្រមទាំងបង្កើត ឱ្យបាននូវ ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយៗ សម្រាប់កម្ពុជា»។

សម្ដេចនាយករដ្ឋមន្ត្រីបន្ថែមថា រាជរដ្ឋាភិបាលបន្តផ្ដល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញនេះជូនប្រជាជនដោយឥតគិតថ្លៃ ដូចការចាក់វ៉ាក់សាំងនៅជុំទី១ ដែរ។ ទន្ទឹមនេះ ដើម្បីបង្កើនល្បឿននៃការចាក់ វ៉ាក់សាំងដូសជំរុញនេះ ក៏ដូចជាដើម្បីកាត់បន្ថយបន្ទុកចំណាយថវិកាជាតិ, រាជរដ្ឋាភិបាលលើកទឹកចិត្ត និង អំពាវនាវដល់ប្រជាជនដែលមានលទ្ធភាពគ្រប់គ្រាន់ ឱ្យទៅទទួលយកការចាក់វ៉ាក់សាំងដូសជំរុញនេះ នៅតាម គ្រឹះស្ថានសុខាភិបាលឯកជន ដែលទទួលបានការអនុញ្ញាតឱ្យផ្ដល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ នេះ។

ដោយឡែក បណ្ដារោងចក្រ-សហគ្រាស និងម្ចាស់អាជីវកម្មទាំងអស់ ក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមចំណែក ចែករំលែកបន្ទុកចំណាយជាមួយរាជរដ្ឋាភិបាល ក្នុងការផ្ដល់ការចាក់វ៉ាក់សាំងដូសជំរុញនេះដល់បុគ្គលិក និង កម្មករ-និយោជិតរបស់ខ្លួនឱ្យបានគ្រប់គ្នា ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅតាម រោងចក្រ-សហគ្រាស និងទីតាំងអាជីវកម្ម និងធានាបាននូវសុវត្ថិភាព និងនិរន្តភាពនៃកិច្ចដំណើរការផលិតកម្ម ជាប្រក្រតីនៅក្នុងរោងចក្រ-សហគ្រាស ឬអាជីវកម្មរបស់ខ្លួន។

ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំផែនការលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩ ដុសជំរុញនេះ ក៏បានឱ្យគណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩ ត្រូវបន្តយកមិត្តចិនធ្វើជាបង្អែកផ្អែកយុទ្ធសាស្ត្រក្នុងការផ្គត់ផ្គង់វ៉ាក់សាំងដល់កម្ពុជា ហើយប្រភពផ្សេងទៀត នៅបន្តជាប្រភពគាំទ្រ។

រាជរដ្ឋាភិបាលសង្ឃឹមនិងជឿជាក់ថា ប្រជាពលរដ្ឋ និងវិស័យឯកជននឹងបន្តចូលរួមផ្ដល់កិច្ចសហការជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយចាក់ វ៉ាក់សាំងដូសជំរុញនេះ ឱ្យមានប្រសិទ្ធភាព ដើម្បីបង្កើតឱ្យមានភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយៗ ក្នុងការទប់ទល់នឹងមេរោគកូវីដ-១៩ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពារអាយុជីវិតប្រជាជន និងសម្រាប់ ឈានឆ្ពោះទៅកាន់ផែនការនៃការបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅ ជាមួយនឹងវត្តមានជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី៕











# អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ចុះសួរសុខទុក្ខ និងប្រទានពរប្រជាពលរដ្ឋតាមផ្ទះ

*អត្ថបទ៖ ព្រះសហគមន៍កំពង់ចាម*

លោកប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានចុះសួរសុខទុក្ខ និងប្រទានពរតាមផ្ទះប្រជាពលរដ្ឋចំនួន៤៥គ្រួសារ កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១ ក្នុងតំបន់ភូមិព្រែកខ្សាយ(ខ) ស្រុក ពាមរក៍ ខេត្តព្រៃវែង។

ការចុះសួរសុខទុក្ខនិងប្រទានពរតាមផ្ទះនេះ គឺលោកអភិបាលបានធ្វើឡើងនៅតាមផ្ទះរបស់ប្រជាពលរដ្ឋទាំងគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទ ក្នុងតំបន់ភូមិព្រែកខ្សាយ(ខ) នេះ។

ការចុះធ្វើសកម្មភាពនេះ ដោយសារមូលហេតុថា បញ្ហានៃការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ នៅមិនទាន់ស្រាកស្រាននៅឡើយទេ ដែលធ្វើឱ្យបងប្អូនគ្រីស្តបរិស័ទមិនបានចូលរួមថ្វាយអភិបូជាទាំងថ្ងៃអាទិត្យ និងបុណ្យផ្សេងៗក្នុងព្រះសហគមន៍។

លោក អភិបាល ប្រ៊ុយណូ កូសម៍ បានមានប្រសាសន៍ថា ៖ «ជាពិសេសពួកគេមានការបាក់ទឹកចិត្ត ពួកគេត្រូវការអាហារខាងផ្លូវវិញ្ញាណបន្ថែមក្រៅពីអាហារប្រចាំថ្ងៃដោយហេតុនេះ យើងបានចំណាយពេលវេលាខ្លះដើម្បីចែករំលែកសេចក្តីស្រឡាញ់ សួរសុខទុក្ខគ្នា លើកទឹកចិត្ត អធិដ្ឋានរួមគ្នា ដើម្បីឲ្យបងប្អូនទាំងអស់មានសេចក្តីសង្ឃឹម និងតស៊ូក្នុងជីវិតរស់នៅក្នុងជំនឿតែមួយ»៕













# ព្រះសហគមន៍កាតូលិកមណ្ឌលគិរី ជួយដល់គ្រួសារស្ត្រីមេម៉ាយមួយរូប






*អត្ថបទ៖ ព្រះសហគមន៍កាតូលិកមណ្ឌលគិរី*

សមាជិកសន្ត វ៉ាំងសង់ ដឺប៉ូល បានចុះសួរសុខទុក្ខស្ត្រីមេម៉ាយម្នាក់ ដែលកំពុងតែរស់នៅជាមួយនឹងកូនប្រុសចំនួន៣នាក់ ដែលមានជីវភាពខ្វះខាត នៅក្នុងភូមិឡាំម៉េះ ឃុំប៊ូស្រា ស្រុកពេជ្រដា ខេត្តមណ្ឌលគិរី ។

ការចុះសួរសុខទុក្ខ និងនាំយកនូវស្បៀងអាហារមួយចំនួនជូនស្ត្រីមេម៉ាយ ឆេង យៀង អាយុ៤៥ឆ្នាំ នេះ ធ្វើឡើងកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១ ។ សមាជិកសន្ត វ៉ាំងសង់ ដឺប៉ូល បាននាំយកនូវអំណោយខ្លះៗរួមមានជូនដល់ស្ត្រីរូបនេះ ដោយរួមមាន អង្ករ៥០គីឡូក្រាម និងគ្រឿងបរិភោគមួយចំនួនផង។

ទន្ទឹមនឹងនោះដែរ ដោយមើលឃើញពីសភាពខ្វះខាតក្នុងការរស់នៅរបស់ស្ត្រីមេម៉ាយរូបនេះ បូជាចារ្យនៃព្រះសហគមន៍មណ្ឌលគិរី លោកហ្វ្រង់ស័រ អេមេល្បដាល ក៏បានដឹកនាំក្រុមយុវជន ចុះជួយជួសជុលផ្ទះតាមផ្នែកខ្លះរបស់ស្ត្រីរូបនេះ ដូចជាការ បាំងបិទជញ្ជាំង និងដំបូលផ្ទះជាដើម៕

# អ្នកនាង សយ ស្រីនី ៖ «ព្រះជាម្ចាស់តែងតែស្ដាប់ពីការអធិដ្ឋានរបស់ខ្ញុំ»

*អត្ថបទ៖ ឆាក លាំង*

អ្នកនាង សយ ស្រីនី វ័យ៤០ឆ្នាំ ជាកូនស្រីទី១ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៥នាក់ ក្នុងគ្រួសារពុទ្ធបរិស័ទរស់នៅភូមិតារាជ ឃុំត្រពាំងរាំង ស្រុកជុំគិរី ខេត្តកំពត។ សព្វថ្ងៃអ្នកនាង មានជំនឿលើសាសនាព្រះគ្រីស្ត។

ជាស្ត្រីមេផ្ទះរស់នៅជុំជាមួយស្វាមី និងកូនៗ អ្នកនាង ស្រីនី បានឲ្យដឹងថា នាងបានស្គាល់ព្រះសហគមន៍កាតូលិក តាមរយៈសកម្មភាពមនុស្សធម៌ផ្សេងៗនៅក្នុងភូមិដែលគាត់រស់នៅតាំងពីចន្លោះឆ្នាំ១៩៩៧មក។ ការចុះជួយប្រជាជនក្រីក្រនៅក្នុងភូមិ ដោយមិនប្រកាន់ពូជសាសន៍ និងសាសនា បានធ្វើឲ្យអ្នកនាង ចាប់អារម្មណ៍ចង់ដឹង ចង់ស្គាល់ពីព្រះយេស៊ូ ហើយក៏ចាប់ផ្ដើមចូលស្វែងយល់ជំនឿជាមួយលោកបូជាចារ្យ និងគ្រូបអប់រំជំនឿ រហូតដល់ឆ្នាំ២០០៨ក៏ទទួលអគ្គសញ្ញាជ្រមុជនៅព្រះសហគមន៍ ជុំគិរី ក្នុងមណ្ឌលសកម្មភាពកំពត ខេត្តកំពត។



អ្នកនាង សយ ស្រីនី បានបន្តថា ក្រោយពីបានផ្លាស់ប្ដូរជំនឿ គាត់មានជីវិតថ្មីមួយបែបទៀត។ អ្នកនាងថា ៖ «ខ្ញុំមានអំណរសប្បាយ មានសេចក្ដីក្លាហាន យើងដឹងច្បាស់ខ្លួនឯងថា យើងមានព្រះជាម្ចាស់គង់ជាមួយជនិច្ច»។

ជាសមាជិកមួយរូបក្នុងក្រុមស្ត្រីជោគជ័យនៃព្រះសហគមន៍ជុំគីរីបាន អ្នកនាងបានបន្តថា ក្នុងជីវិតជាគ្រីស្តបរិស័ទសព្វថ្ងៃនេះ គាត់បានជួបជាមួយនឹងបញ្ហាមួយក្នុងជីវិត ប៉ុន្តែព្រះជាម្ចាស់មិនឱ្យគាត់រាថយនោះឡើយ។ ការអធិដ្ឋានជាកំលាំងជំរុញទឹកចិត្តខ្លាំងមែនទែន ដើម្បីបន្តដំណើរទៅមុខជាមួយព្រះអង្គ។ អ្នកនាង យស ស្រីនី បានប្រាប់ថា ៖ «ព្រះវិហារដូចជាផ្ទះរបស់ខ្ញុំ ព្រះវិហារតែងផ្ដល់សេចក្ដីសុខ និងភាពកក់ក្ដៅដល់ខ្ញុំពេលមានទុក្ខលំបាក»។

អ្នកនាង សយ ស្រីនី បានបង្ហាញពីជំនឿរបស់ខ្លួនយ៉ាងមុតមាំ និងស្មោះស្ម័គ្រជាមួយព្រះជាម្ចាស់ទៅថ្ងៃអនាគតគឺ ៖ «ស្រលាញ់ព្រះជាម្ចាស់ព្យាយាមបន្តជំនឿទៅអ្នកដទៃ ខិតខំបម្រើបងប្អូនដែលជួបការលំបាកក្នុងជីវិត»៕

# ព្រះសហគមន៍បាត់ដំបង និងព្រះសង្ឃពុទ្ធសាសនា រួមគ្នាដាំនិងបំបួសដើមឈើ




*អត្ថបទ៖*

ព្រះសហគមន៍កាតូលិកបាត់ដំបងបានរៀបចំកម្មវិធីដាំដើមឈើ និងបំបួសដើមពោធិ៍២ដើម ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកអភិបាលទេព ច័ន្ទពិសិដ្ឋ លោកបូជាចារ្យ ព្រះសង្ឃសមណនិស្សិត និងសិស្សមណ្ឌលអារូប៉េផងដែរ។

ក្នុងពិធីនោះ លោកអភិបាលទេព ច័ន្ទពិសិដ្ឋ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា ៖ «យើងរួមគ្នានៅថ្ងៃនេះ នៅក្នុងទ្វារអន្តរជាតិ អធិដ្ឋាន និងការពារថែរក្សាបរិស្ថាន នេះជាឆ្នាំទី៥ហើយដែលយើងរួមគ្នាជាមួយព្រះសង្ឃ បូជាចារ្យកាតូលិក និងបងប្អូនសហការី ដើម្បីលើកទឹកចិត្តគ្នានិងមានសកម្មភាពរួម»។

លោកអភិបាលបានបន្តថា ៖ «យើងមានអំណរសប្បាយដោយព្រះសង្ឃ និងសហការី នៅពុទ្ធិកសកវិទ្យាល័យសីហនុរាជ បានចូលរួមដាំដើមឈើ និងបំបួសដើមពោធិ៍២ដើម ដែលមាននៅក្នុងបរិវេណព្រះសហគមន៍ ដែលនេះជានិមិត្តរូបមួយ នាំឲ្យយើងមានកម្លាំងច្រើន»។

លោកអភិបាលទេព ច័ន្ទពិសិដ្ឋ បានបន្ថែមទៀតថា ការដាំដើមឈើ បច្ចុប្បន្ននេះ ត្រូវថែរក្សាការពារសម្រាប់អនាគត និងបង្ហាញសេចក្តីស្រលាញ់រួមគ្នា ហើយការបំបួសដើមពោធិ៍ ដែលព្រះសង្ឃជួយបំបួស គឺឲ្យគ្រប់គ្នាស្រលាញ់បរិស្ថាន ស្រលាញ់ដើមឈើដែលមាន។

លោកអភិបាលមានប្រសាសន៍ថា ៖ «នេះជាសញ្ញាមួយដែលលើកទឹកចិត្តយើង ឲ្យយើងវាយតម្លៃច្បាស់អំពីបរិស្ថានដែលយើងត្រូវការពារថែរក្សា និងស្រលាញ់ ដោយសារនេះជាព្រះអំណោយទានដែលយើងបានទទួល យើងនៅកណ្តាលបរិស្ថាន យើងស្រលាញ់ជីវិតយើង ដូច្នេះយើងត្រូវថែរក្សា ស្រលាញ់បរិស្ថានដែលយើងមាន»។

ស្របពេលជាមួយគ្នានោះដែរ ព្រះតេជគុណ វី សុវិជ្ជា ជាប្រធានពុទ្ធិកសកលវិទ្យាល័យសីហនុរាជ ក៏បានមានសង្ឃដីកាដែរថា ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ ការប្រារព្ធកម្មវិធីនានាមិនបានធំទូលាយទេ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ប៉ុន្តែទោះជាយ៉ាងនេះក្តី ខាងពុទ្ធិកសកលវិទ្យាល័យសីហនុរាជ ក៏ដូចជាព្រះសហគមន៍កាតូលិកបាត់ដំបង តែងតែមានសកម្មភាពរួមគ្នា ជានិមិត្តរូបនៃមិត្តភាព សន្តិភាព សាមគ្គីភាព ភាតរភាព នៅក្នុងនាមជាប្រជាពលរដ្ឋនៃពិភពលោក។




ព្រះអង្គបានបន្តថា ៖ «ទោះយើងមានជំនឿខុសគ្នាយ៉ាងណា យើងមានសញ្ជាតិខុសគ្នាយ៉ាងណាក៏ដោយ ប៉ុន្តែយើងជាមនុស្សដូចគ្នាដែលកើតឡើងនៅក្នុងភពផែនដីនេះ យើងត្រូវតែហៅរកគ្នាដើម្បីឲ្យមានការឯកភាព សាមគ្គីភាព ជានិមិត្តរូបដែលយើងជាថ្នាក់ដឹកនាំសាសនា យើងអាចគិតថាជាផ្នែកមួយដ៏សំខាន់ នៅក្នុងការធ្វើឲ្យបរិស័ទនៃសាសនានីមួយៗ មានការស្រលាញ់គ្នាទៅវិញទៅមក»។

ព្រះតេជគុណ វី សុវិជ្ជា មានសង្ឃដីកាបន្តថា ថ្ងៃនេះ សាសនាទាំងពីរបានធ្វើសកម្មភាពរួមគ្នា ដូចជាការដាំដើមឈើ និងបំបួសដើមពោធិ៍បែបអន្តរសាសនា។ សកម្មភាពនេះ ធ្វើឡើងសម្រាប់បង្ហាញប្រាប់ប្រជាពលរដ្ឋថា ដើមឈើគឺជាជីវិតទាំងអស់គ្នា ទាមទារឲ្យមានការគោរព។

ព្រះតេជគុណ វី សុវិជ្ជា បានបញ្ជាក់ថា ៖ «នៅក្នុងតម្លៃនៃព្រះពុទ្ធសាសនា នៅក្នុងម្លប់មួយនៃម្លប់ទាំងប្រាំមួយ គឺរុក្ខឆ័យា ការយកម្លប់ជាទីពឹងទីរលឹកយើងចាំបាច់ត្រូវតែថែទាំដើមឈើ ឲ្យបានគង់វង្សមិនមែនតែដើមឈើនៅតាមគេហដ្ឋានទេ ប៉ុន្តែយើងត្រូវចងចាំថាដើមឈើគឺជាម្លប់នៃជីវិតរបស់យើងទាំងអស់គ្នា ជានិមិត្តរូបនៃពិភពលោក»។

ព្រះតេជគុណបន្តថា ៖ «សូមឲ្យយើងគិតគូរយកដើមឈើជាទីពឹង ជាទីពំនាក់របស់យើង និងថែរក្សាដើមឈើដើម្បីជាប្រយោជន៍រួមរបស់មនុស្សជាតិ ព្រោះដើមឈើមានប្រយោជន៍ណាស់ សម្រាប់អាយុជីវិតរបស់យើង និងផ្តល់អ្វីគ្រប់យ៉ាងឲ្យយើង ។ ដូច្នេះសូមបងប្អូនគ្រប់និនាការទាំងអស់ យើងរួបរួមគ្នាដើម្បីការពារថែរក្សាដើមឈើ និងបរិស្ថានធម្មជាតិ»។

គួរបញ្ជាក់ផងដែរថា ព្រះសហគមន៍កាតូលិកបាត់ដំបង តែងតែរៀបចំកម្មវិធីនេះឡើងជារៀងរាល់ឆ្នាំ ជាកម្មវិធីផ្នែកអន្តរសាសនា រួបរួមគ្នាថែរក្សាការពារបរិស្ថាន ហើយនេះជាលើកទី៥ហើយ ដែលព្រះសហគមន៍ និងពុទ្ធិកសកលវិទ្យាល័យសីហនុរាជ សាខាខេត្តបាត់ដំបងបានរួមគ្នាដាំដើមឈើនេះ៕










# ពិធីថ្វាយខ្លួនរបស់កូនសិស្សលោកអភិបាលសម្រាប់ឆ្នាំសិក្សាថ្មី



*អត្ថបទ៖ ព្រះសហគមន៍ភ្នំពេញ*

នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច កូនសិស្ស ប៉ូល នួន ប៉ូល (បរិញ្ញាបត្ររងឆ្នាំទី ១) និងណារ៉ា(ថ្នាក់ទី ១០) បានស្ម័គ្រចិត្តត្រៀមខ្លួនចូលទេវវិទ្យាល័យ ដោយស្នាក់ក្នុងព្រះវិហារ ដើម្បីហ្វឹកហាត់ខ្លួនតាមគោលការអប់រំ ដែលរួមមាន ភាពជាមនុស្សគួរសម(Human formation), ខាងផ្លូវវិញ្ញាណ(Spiritual formation), ចំណេះចេះដឹង(Intellectual formation) និងការណែនាំថែទាំព្រះសហគមន៍និងការប្រកាសដំណឹងល្អ(Pastoral&Evangelization formation)។

សូមបងប្អូនជួយគាំទ្រ ដោយពាក្យអធិដ្ឋាន អាហារ និងបច្ច័យ ឬជួយជំរុញលើកទឹកចិត្តការត្រាស់ហៅជាបូជាចារ្យដល់កូនចៅ។ លោកបូជាចារ្យ ឆ័ត្រសិរី បានធ្វើការស្វាគមន៍យ៉ាងកក់ក្តៅដល់កូនសិស្សទាំងពីរផងដែរ។

# គ្រួសារស្រឡាញ់ឈើឆ្កាងព្រះយេស៊ូទទួលណូវីស៣រូប

*អត្ថបទ៖ ព្រះសហគមន៍ភ្នំពេញ*

ក្រុមគ្រួសារដូនជី អ្នកស្រឡាញ់ឈើឆ្កាងព្រះយេស៊ូក្នុងភូមិភាគកំពង់ចាម បានរៀបចំកម្មវិធីទទួលណូវីសចំនួន៣រូប ដើម្បីអប់រំក្លាយជាដូនជីកាតូលិកនាពេលខាងមុខ នាថ្ងៃដែលព្រះសហគមន៍កាតូលិកសកលប្រារព្ធបុណ្យលើកតម្កើងឈើឆ្កាងព្រះយេស៊ូ នៅថ្ងៃទី១៤ ខែកញ្ញាឆ្នាំ២០២១ នៅផ្ទះណូវីសក្នុងក្រុងកំពង់ចាម។




យុវនារីទាំងបីរូបនោះរួមមាន តេរេសាឃឹម សុខា ជាណូវីសឆ្នាំដំបូង និងពីររូបទៀត គឺក្លារ៉ាយាន កញ្ញា និងក្លារ៉ាដូត ស្រីឡៃ ជាណូវីសឆ្នាំបញ្ចប់។

កម្មវិធីនេះ រៀបចំឡើងក្រោមអធិបតីភាពរបស់លោកអភិបាលប៊្រុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

អភិបាលប៊្រុយណូ មានប្រសាសន៍ថា លោកសូមអរគុណក្រុមបងស្រីនិងអស់អ្នកដែលបានគាំទ្រទាំងកំលាំងកាយនិងចិត្ត និងអរព្រះគុណព្រះជាម្ចាស់ដែលនាំឲ្យយុវនាទីបីនាក់ស្គាល់ផ្លូវមួយសម្រាប់ជីវិត។

លោកអភិបាលបន្ថែមថា «សូមបងស្រីបង្ហាញផ្លូវដល់យើង បន្តផ្តល់សក្ខីភាពអំពីគម្រោងការណ៍ដ៏ពិសេសរបស់ព្រះជាម្ចាស់តាមរយៈឈើឆ្កាង ឲ្យយើងយល់កាន់តែច្បាស់គម្រោងការណ៍របស់ព្រះអង្គសម្រាប់យើងទាំងអស់គ្នា»។

តេរេសា ឃឹម សុខា ជាបេក្ខនារី ណូវីសឆ្នាំទី១ បានឲ្យដឹងថា ឆន្ទៈរបស់គាត់គឺធ្វើជាដូនជីកាតូលិក ទោះបីជាក្រុមគ្រួសារអ្នកបួសរបស់គាត់ត្រូវបានរំសាយកាលពីឆ្នាំ២០១៧ គឺក្រោយ២ឆ្នាំ ដែលយុវនារីរូបនេះ បានថ្វាយពាក្យសច្ចាប្រណិធានលើកដំបូងរួច។

ក្នុងរយៈពេល៤ឆ្នាំមកនេះ សុខាបានទៅកន្លែងជាច្រើនរបស់ក្រុមគ្រួសារអ្នកបួស ដើម្បីស្វែងរកការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះគាត់។ ទោះបីវ័យ៣៧ឆ្នាំហើយក៏ដោយ ក៏នាងនៅតែមានចិត្តសង្ឃឹមជានិច្ច និងជឿជាក់លើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ក្នុងជីវិតជាអ្នកបួស។

តេរេសា ឃឹម សុខា បានឲ្យដឹងថា ក្រុមគ្រួសារថ្មីនេះមាន លក្ខណៈជាបងប្អូន ដោយបម្រើព្រះសហគមន៍ និងស្តាប់បង្គាប់លោកអភិបាល ដូចគ្នានឹងសច្ចាទាំងបី ដែលគាត់បានធ្វើជាមួយក្រុមគ្រួសារព្រះមាលា។ យុវនារីរូបនេះបញ្ជាក់ថា «អ្វីដែលនាងខ្ញុំទទួលគឺបងស្រីនៅទីនេះ ជាជនជាតិខ្មែរ។ ពេលបងស្រីថារីនណែនាំ គាត់ប្រើភាសាខ្មែរ គាត់បង្រៀន ហើយគាត់ធ្វើ អីចឹងខ្ញុំយល់ច្រើនជាងដែលខ្ញុំរស់នៅជាមួយបរទេស»។

សុខា បានរំលឹកអំពីទិសដៅរបស់គាត់យ៉ាងដូច្នេះថា «អ្វីដែលឲ្យខ្ញុំបន្តនិងមានក្តីសង្ឃឹមដល់សព្វថ្ងៃនេះ គឺខ្ញុំនឹកឃើញពាក្យសច្ចារបស់ខ្ញុំ ដែលបានសច្ចាលើកដំបូងជាមួយព្រះជាម្ចាស់ នៅក្រុមគ្រួសារបងស្រីព្រះមាលា។ ដូច្នេះ ខ្ញុំចង់គោរពនិងចង់បម្រើព្រះអង្គ តាមអ្វីដែលនាងខ្ញុំ(ត្រូវ)លីឈើឆ្កាងបន្តទៀត»។

ក្លារ៉ា យាន កញ្ញា ជាណូវីសឆ្នាំទី២ ដែលជាឆ្នាំបញ្ចប់ការសិក្សា ត្រៀមខ្លួនដើម្បីថ្វាយពាក្យសច្ចាប្រណិធាន នាពេលខាងមុខនេះ បានឲ្យដឹងថា គាត់នឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណារស់នៅស្របតាមការណែនាំរបស់ក្រុមគ្រួសារអ្នកបួស តាមព្រះបន្ទូលរបសព្រះជាម្ចាស់ «និងធ្វើឲ្យដំណើរជីវិតនៃការត្រាស់ហៅនេះ រស់រវើក និងបន្តដំណើរពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីក្លាយជាបងស្រីនាពេលអនាគត»។

ក្រុមដូនជីមានវត្តមាននៅក្នុងប្រទេសកម្ពុជាជាលើកទី២ ក្នុងអំឡុងឆ្នាំ១៩៩០ ដោយមានដូនជីនកាតូលិកក្រុមគ្រួសារអ្នកស្រលាញ់ព្រះឈើឆ្កាងមកពីប្រទេសថៃ មកតាំងនៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម គឺលោកយាយ សាវីយេ និង លោកយាយប៉េឡាជី។ បច្ចុប្បន្នក្រុមគ្រួសារនេះ មានសមាជិកដូនជីបម្រើការងារនៅក្នុងភូមិភាគកំពង់ចាមចំនួន៦នាក់ និងមានណូវីសចំនួន៣នាក់។ ចំពោះដូនជីពីររូបដែលមកពីប្រទេសថៃនាទសវត្សទី៩០ លោកយាយ សាវីយេ និងលោកយាយប៉េឡាជី បានវិលត្រលប់ទៅប្រទេសថៃវិញ នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៨។

# លោកអូលីវីយេ ៖ «ក្នុងវិបត្តិកូវីដនេះ ជីវិតយើងដូចជាមិនធម្មតា ប៉ុន្តែម្នាក់ៗនៅត្រូវតែបន្តទៅមុខដដែល»





ទោះបីជាប្រទេសកម្ពុជា ក៏ដូចជាពិភពលោកទាំងមូល ស្ថិតនៅក្រោមការរឹតបន្តឹងយ៉ាងតឹងរ៉ឹងដោយសារការរាតត្បាតនៃមេរោគកូវីដ១៩ និងជីវិតដូចជាមិនធម្មតាក៏ដោយ ក៏ប៉ុន្តែម្នាក់ៗនៅត្រូវតែបន្តទៅមុខដដែល។ នេះជាការលើកឡើងរបស់លោកអភិបាល អូលីវីយេ ជ្មឹតហាស្លេ អភិបាលភូមិភាគភ្នំក្នុងពិធីថ្វាយអភិបូជាសម្រាប់ភូមិភាគទាំងមូល ដែលលោកធ្វើជារៀងរាល់ថ្ងៃអាទិត្យពីខែកុម្ភៈមកម្ល៉េះ ពីព្រះសហគមន៍សន្តីម៉ារីញញឹម តាកែវ។

នៅថ្ងៃចន្ទ ទី០២ ខែសីហា ឆ្នាំ២០២១ លោកអភិបាលអូលីវីយេ បានជួយកិនស្រូវ ច្រូតស្រូវខ្លះ និងសួរសុខទុក្ខនៅវត្ត និងភូមិសុខសាន្ត។ ថ្ងៃអង្គារ ទី០៣ ខែសីហា ឆ្នាំ២០២១ លោកបានឧបត្ថម្ភអំណោយដល់សាលាស្រុកត្រាំកក់ ដោយសារគេបានបិទផ្សារ និង ២០០នាក់មានវិជ្ជមានកូវីដ១៩។

នៅថ្ងៃពុធ ទី៤ ខែសីហា ឆ្នាំ២០២១ លោកបានទស្សនកិច្ចនៅចំការហានសួគ៌ និងជួយរៀបចំភោជនីយដ្ឋានថ្មី និងដាំដើមឈើហូបផ្លែខ្លះ និងក៏បានឆ្លៀតឱកាសដើម្បីចូលរួមនៅក្នុងសិក្ខាសាលាអន្តរជាតិតាមហ្សូម ដែលរៀបចំឡើងដោយវិទ្យាស្ថានសន្តប៉ូល ស្តីអំពី ផលប៉ះពាល់នៃកូវីដ១៩លើវិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។

សម្រាប់ថ្ងៃព្រហស្បតិ៍ ទី០៥ ខែសីហា ឆ្នាំ២០២១ លោកអភិបាលបានចូលរួមតាមហ្សូមជាមួយបងស្រីសាឡេស៊ាន ដែលបានថ្វាយពាក្យសច្ចាដំបូងរបស់បងស្រី Charlene។ ថ្ងៃសៅរ៍ ទី០៧ ខែសីហា ឆ្នាំ២០២១ លោកអូលីវីយេ បានប្រជុំជាមួយការិយាល័យយុវជនតាមហ្សូម (Zoom) និងតំណាងយុវជនខ្លះ ដើម្បីរៀបចំមហាសន្និបាតអនឡាញលើកទី១ ដែលត្រូវប្រព្រឹត្តឡើងនៅខែកញ្ញាខាងមុខនេះ និងបានពិភាក្សា មានយោបល់ច្រើន។

លោកអភិបាលបានថ្លែងថា ៖ «នៅពេលរសៀលខ្ញុំបានចូលរួមនៅក្នុងសិក្ខាសាលាជាមួយអាស៊ីជាង ១០ប្រទេស នៅក្នុងចលនាអធិដ្ឋានសម្រាប់ប្រទេសមីយ៉ាន់ម៉ា យើងបានចូលរួម ២៥នាក់ពីប្រទេសកម្ពុជានៅក្នុងចំណោមសមាជិក ១៥០នាក់»។

លោកអូលីវីយេ បានបញ្ជាក់ទៀតថា ៖ «ពិតមែន ដោយការអធិដ្ឋានយើងអាចលើកភ្នំពីកន្លែងមួយទៅកន្លែងមួយដើម្បីបញ្ចប់ថ្ងៃនេះ យើងបានអធិដ្ឋាន តែហ្សេដើម្បីផ្ញើជីវិត សេចក្តីសង្ឃឹម ការភ័យខ្លាចរបស់យើងទៅលើព្រះបិតារបស់យើង»៕







# *យើងជាគ្រួសារតែមួយ!*

ព្រះសហគមន៍កាតូលិករបស់យើងជាគ្រួសារដ៏ធំធេងមួយ នៅក្នុងទុក្ខលំបាកកូវីដ-១៩នេះ
យើងយកចិត្តទុកដាក់ជួយគ្នាទៅវិញទៅមក និងចែករំលែកសេចក្ដីស្រលាញ់ដល់បងប្អូនរបស់យើង។
ព្រះសហគមន៍ជួយដល់អ្នកត្រូវការអំឡុងពេលដែលយើងរួមគ្នាប្រយុទ្ធនឹងជំងឺកូវីដ-១៩។

## សកម្មភាពនានានៃព្រះសហគមន៍ភូមិភាគភ្នំពេញ



## សកម្មភាពព្រះសហគមន៍ភូមិភាគបាត់ដំបង



## សកម្មភាព នានានៃព្រះសហគមន៍ភូមិភាគកំពង់ចាម

